

តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL
Cambodia

# ករណីសិក្សាអំពី ប្រព័ន្ធពន្ធដារ នៅប្រទេសកម្ពុជា

អង្គការតម្លាភាពកម្ពុជា

# អង្គការតម្លាភាពកម្ពុជា

អាសយដ្ឋាន ៖ ផ្ទះលេខ ៣ ផ្លូវលេខ ៣៩០ សង្កាត់បឹងកេងកង ៣ ខណ្ឌចំការមន ក្រុងភ្នំពេញប្រទេសកម្ពុជា

ទូរស័ព្ទ ៖ (+៨៥៥) ២៣ ២១៤ ៤៣០

គេហទំព័រក្នុងប្រទេស ៖ www.ticambodia.org

គេហទំព័រនៅការិយាល័យកណ្តាល៖ www.transparency.org


អង្គការតម្លាភាពកម្ពុជា គឺជាសាខាក្នុងប្រទេសមួយដែលមានការទទួលស្គាល់ពេញលេញរបស់អង្គការតម្លាភាពអន្តរជាតិ និងត្រូវបានបង្កើតឡើងជាផ្លូវការនៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ ២០១០ ដោយសកម្មជនប្រឆាំងអំពើពុករលួយ និងអ្នកជំនាញជាច្រើនដែលប្តេជ្ញាបង្កើតសង្គមកម្ពុជាប្រកបដោយតម្លាភាព និងគណនេយ្យភាព។ ចាប់ពីពេលនោះមក អង្គការនេះបានបង្កើតជាស្ថាប័នដ៏រឹងមាំមួយដែលប្រយុទ្ធប្រឆាំងអំពើពុករលួយ និងលើកកម្ពស់សុចរិតភាព តម្លាភាព និងគណនេយ្យភាពក្នុងប្រទេស។

យើងសហការជាមួយបុគ្គល និងស្ថាប័នជាច្រើននៅគ្រប់កម្រិត ដូចជា រដ្ឋាភិបាល សង្គមស៊ីវិល អាជីវកម្ម ប្រព័ន្ធផ្សព្វផ្សាយ និងសាធារណជនដើម្បីសម្រេចបានការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព លើកកម្ពស់សុចរិតភាព និងប្រឆាំងអំពើពុករលួយ។

ឯកសារនេះត្រូវបានរៀបរៀងឡើង ដោយទទួលបានជំនួយហិរញ្ញវត្ថុពីសហភាពអឺរ៉ុប ប្រទេសស៊ុយអែត និងប្រទេសស្វីស។ ទស្សនៈដែលលើកឡើងក្នុងឯកសារនេះមិនឆ្លុះបញ្ចាំងពីទស្សនៈផ្លូវការរបស់សហភាពអឺរ៉ុប ប្រទេសស៊ុយអែត ឬប្រទេសស្វីសឡើយ។

រូបភាពនៅលើគម្របឯកសារ គឺជាស្នាដៃរបស់ Phalinn Ooi ដែលស្ថិតក្រោមអាជ្ញាប័ណ្ណ Creative Commons ។

© រក្សាសិទ្ធដោយ អង្គការតម្លាភាពកម្ពុជា ឆ្នាំ២០១៦

SWEDEN

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

# មាតិកា

១. សេចក្តីផ្តើម......5

២. គោលបំណងនៃការសិក្សាស្រាវជ្រាវ......6

៣. ការសិក្សាលើឯកសារពាក់ព័ន្ធនានា......6

៤. វិធីសាស្ត្រនៃការសិក្សា......10

៥. ប្រព័ន្ធពន្ធដារនៅប្រទេសកម្ពុជា......10

៥.១ ទិដ្ឋភាពទូទៅ......10

៥.២ ការចុះបញ្ជីពន្ធដារ......12

៥.២.១ អ្នកជាប់ពន្ធតូច......13

៥.២.២ អ្នកជាប់ពន្ធមធ្យម និងធំ......16

៥.៣ ការរីកចម្រើននាពេលថ្មីៗបំផុតរបស់អគ្គនាយកដ្ឋានពន្ធដារ......18

៥.៣.១ ការលុបចោលនូវពន្ធកាត់ទុកលើអត្ថប្រយោជន៍បន្ថែមសម្រាប់អាជីវកម្មទាំងអស់......18

៥.៣.២ ការចុះពិនិត្យមើលសហគ្រាស( ទាំងចុះបញ្ជី និងមិនចុះបញ្ជី )នៅប្រទេសកម្ពុជា......18

៥.៣.៣ ការកែប្រែកម្រិតពន្ធលើប្រាក់បៀវត្សអប្បបរមា......18

៦. បរិយាកាសពន្ធដារចេញពីទស្សនៈប្រឆាំងអំពើពុករលួយ......19

៦.១ ទស្សនៈរបស់ក្រុមហ៊ុនដែលបានបង់ពន្ធ......19

៦.២ ទស្សនៈរបស់ក្រុមហ៊ុនដែលមិនបានបង់ពន្ធ......23

៦.២.១ ការខ្វះការយល់ដឹងពីប្រព័ន្ធពន្ធដារ និងបទប្បញ្ញត្តិនានា......24

៦.២.២ ការយល់ឃើញខ្ពស់ចំពោះអំពើពុករលួយ......25

៦.២.៣ លទ្ធភាពប្រកួតប្រជែងទាប......25

៦.២.៤ ភាពស្មុគស្មាញនៃច្បាប់ពន្ធដារ......25

៦.២.៥ ការលំបាករបស់បុគ្គល/សម្ពាធកាតព្វកិច្ច......25

៦.២.៦ កង្វះតម្លាភាពក្នុងការផ្តល់សេវាសាធារណៈ និងទំនិញ......26

៧. មូលហេតុនិងផលប៉ះពាល់នៃអំពើពុករលួយមកលើប្រព័ន្ធពន្ធដារ......26

៧.១ មូលហេតុនៃអំពើពុករលួយ......26

៧.១.១. ភាពស្មុគស្មាញនៃច្បាប់ពន្ធដារ......25

៧.១.២ អំណាចផ្តាច់មុខរបស់មន្រ្តីពន្ធដារ ........ 26

៧.១.៣ ផលប្រយោជន៍ទៅវិញទៅមក ........ 26

៧.១.៤ ប្រព័ន្ធបរិបាលកិច្ច ........ 26

៧.១.៥ ទម្លាប់នៃការបង់ប្រាក់សម្រាប់ការសម្របសម្រួល ........ 27

៧.១.៦ បរិយាកាសទូទៅនៅក្នុងរដ្ឋបាលសាធារណៈ ........ 27

៧.២ ផលប៉ះពាល់នៃអំពើពុករលួយលើប្រព័ន្ធពន្ធដារ ........ 27

៨. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ........ 29

៩. ឯកសារយោង ........ 32

១០. ឧបសម្ព័ន្ធ ........ 34

# អក្សរកាត់

| | | |
|---|---|---|
| BIP | Business Integrity Programme | កម្មវិធីសុចរិតភាពធុរកិច្ច |
| CTA | Committee of Tax Arbitration | គណៈកម្មាធិការសម្រុះសម្រួលសារពើពន្ធ |
| EUROCHAM | European Chamber of Commerce | សភាពាណិជ្ជកម្មសហភាពអឺរ៉ុប |
| EAP | East Asia and the Pacific | អាស៊ីខាងកើត និងប៉ាស៊ីហ្វិក |
| GDCE | General Department of Customs and Excise | អគ្គនាយកដ្ឋានគយ និងរដ្ឋាករ |
| GDT | General Department of Taxation | អគ្គនាយកដ្ឋានពន្ធដារ |
| ITC | International Tax Compact | កិច្ចព្រមព្រៀងអន្តរជាតិស្តីពីពន្ធ |
| KHR | Khmer Riel | ប្រាក់រៀលខ្មែរ |
| MEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MLVT | Ministry of Labor and Vocational Training | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MoC | Ministry of Commerce | ក្រសួងពាណិជ្ជកម្ម |
| NSSF | National Social Security Fund | បេឡាជាតិរបបសន្តិសុខសង្គម |
| RGC | The Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| QIP | Qualified Investment Project | គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ |
| SME | Small and Medium Enterprise | សហគ្រាសធុនតូច និងមធ្យម |
| TI Cambodia | Transparency International Cambodia | អង្គការតម្លាភាពកម្ពុជា |
| TOP | Tax on Profit | ពន្ធលើប្រាក់ចំណេញ |
| USD | United States Dollar | ប្រាក់ដុល្លារអាមេរិក |
| VAT | Value Added Tax | អាករលើតម្លៃបន្ថែម |

# ១. សេចក្តីផ្តើម

ប្រទេសកម្ពុជាក៏ដូចជាប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀត ព្យាយាមដំនះបញ្ហាសមធម៌សង្គមដែលជាមូលហេតុបង្កឲ្យមានអំពើពុករលួយក្នុងចំណោមមន្ត្រីសាធារណៈ ដែលទារយកកម្រៃមិនផ្លូវការដើម្បីបង្គ្រប់ចំណូលគ្រួសាររបស់ខ្លួន។ អំពើពុករលួយដែលប្រព្រឹត្តិដោយមន្ត្រីសាធារណៈ នៅតែជាឧបសគ្គចំបងមួយសម្រាប់ការធ្វើធុរកិច្ចនៅក្នុងប្រទេសកម្ពុជា។ បរិយាកាសធុរកិច្ចនៅក្នុងប្រទេសកម្ពុជា ត្រូវបានគេមើលឃើញថាកំពុងរងផលវិបាក ពីការចំណាយដែលមិនបានគ្រោងទុក និងការចំណាយថ្លៃដើមខ្ពស់។ ជាពិសេសក្រុមហ៊ុនតូចៗជួបប្រទះនូវបញ្ហាប្រឈមក្នុងបរិយាកាសធុរកិច្ចបែបនេះ។ បច្ចុប្បន្នប្រទេសកម្ពុជាស្ថិតនៅលេខរៀងទី១៥០ ក្នុងចំណោម ១៦៨ ប្រទេសដែលត្រូវបានចាត់ទុកថា មានកម្រិតអំពើពុករលួយខ្ពស់ យោងតាមសន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយរបស់អង្គការតម្លាភាពអន្តរជាតិ [1]។ ដំណើរការនៃការចុះបញ្ជីពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា ត្រូវបានគេចាត់ថាមានលក្ខណៈពុករលួយ និងមិនមានប្រសិទ្ធភាព[2]។ យោងតាមការផ្តល់ចំណាត់ថ្នាក់ផ្នែកសេដ្ឋកិច្ចរបស់ធនាគារពិភពលោកបានបង្ហាញថា ប្រទេសកម្ពុជាស្ថិតនៅលេខរៀងទី១៣១ ក្នុងចំណោម១៨៩ ប្រទេសចំពោះភាពងាយស្រួលក្នុងការធ្វើអាជីវកម្ម [3]។ ប្រទេសកម្ពុជាស្ថិតនៅលំដាប់ទី៥ នៃប្រទេសដែលមានហានិភ័យខ្ពស់ជាងគេបំផុត នៃការសូកប៉ាន់ក្នុងផ្នែកធុរកិច្ច[4]។ ជាងនេះទៅទៀត នៅក្នុងឆ្នាំ២០១៥ ប្រទេសកម្ពុជាគឺជាប្រទេសដែលមានអំពើពុករលួយខ្លាំងជាងគេបំផុតនៅអាស៊ីអាគ្នេយ៍ និងមានចំណាត់ថ្នាក់ស្ថិតនៅលេខរៀងទី១៣៣ ក្នុងចំណោម១៥០ប្រទេស[5]។

រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការអភិវឌ្ឍយ៉ាងល្អប្រសើរក្នុងរយៈពេលជាងមួយទសវត្សរ៍កន្លងមកនេះ ជាមួយនឹងអត្រាកំណើនសេដ្ឋកិច្ចជាមធ្យមប្រមាណជាង៧ភាគរយ និងកំណើនយ៉ាងគំហុកនៃការប្រមូលពន្ធបានដល់ ២៥% ក្នុងឆ្នាំ២០១៥[6]។ ការរីកចម្រើននេះមិនអាចកាត់ផ្តាច់ចេញពីតួនាទីដ៏សំខាន់របស់វិស័យឯកជនបានឡើយ។ ជាក់ស្តែង រាជរដ្ឋាភិបាលកម្ពុជាបានធ្វើកំណែទម្រង់គ្រប់ជ្រុងជ្រោយដើម្បីធ្វើឲ្យ "ការធ្វើអាជីវកម្មនៅក្នុងប្រទេសកម្ពុជា" កាន់តែប្រសើរឡើង តាមរយៈការរៀបចំបច្ចេកវិទ្យាក្នុងការស្វែងរកឈ្មោះពាណិជ្ជកម្មដែលមានលក្ខណៈសាមញ្ញ ដើម្បីជួយសម្រួលដល់ការចុះបញ្ជីពាណិជ្ជកម្ម និងការធ្វើឲ្យនីតិវិធីសារពើពន្ធកាន់តែមានប្រសិទ្ធភាពឡើង។ ច្បាប់ ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០១៦ ដែលបានអនុម័តនៅខែធ្នូ ឆ្នាំ២០១៥ បានលុបចោលនូវពន្ធរបបម៉ៅការ ជំនួសដោយពន្ធរបបពិត (ជាធម្មតាសំដៅលើរបបស្វ័យប្រកាស)។ ជាការពិត កំណែ

[1] អង្គការតម្លាភាពអន្តរជាតិ សន្ទស្សន៍នៃការយល់ឃើញអំពីអំពើពុករលួយឆ្នាំ២០១៥ អាចរកបាននៅៈhttp://bit.ly/1Vq1aQe.

[2] Bertelsmann Transformation Index របាយការណ៍ប្រទេសកម្ពុជា ឆ្នាំ២០១០ អាចរកបាននៅៈhttp://bit.ly/2gBxFjh.

[3] ក្រុមធនាគារពិភពលោក ចំណាត់ថ្នាក់សេដ្ឋកិច្ច ខែមិថុនា ឆ្នាំ២០១៦អាចរកបាននៅៈhttp://bit.ly/K11iGM.

[4] ក្រុមហ៊ុន TRACE International, Inc. 2016 Trace Matrix, អាចរកបាននៅៈhttp://bit.ly/2htlVRw.

[5] ចំណាត់ថ្នាក់អំពើពុករលួយនៃការធ្វើសវនកម្មជាសាកលឆ្នាំ២០១៥អាចរកបាននៅៈhttp://bit.ly/1Xow5gK.

[6] សភាពាណិជ្ជកម្មសហភាពអឺរ៉ុប( EuroCham) សៀវភៅស ស្តីពីអានុសាសន៍លើគោលនយោបាយពាណិជ្ជកម្ម និងការវិនិយោគ ខែមីនា ឆ្នាំ២០១៦អាចរកបាននៅៈhttp://bit.ly/2hrCA56. P.26.

ទម្រង់នេះបានលើកទឹកចិត្តដល់ក្រុមហ៊ុននានាឲ្យអនុវត្តតាមច្បាប់កាន់តែច្រើន ប៉ុន្តែវាក៏បានបង្កើតនូវការយល់ច្រឡំមួយចំនួន ដោយសារតែកង្វះខាតនូវព័ត៌មាន និងការយល់ដឹងអំពីនីតិវិធីសារពើពន្ធ។

ស្របតាមកម្មវិធីសុចរិតភាពធុរកិច្ចរបស់អង្គការតម្លាភាពកម្ពុជា និងដើម្បីគាំទ្រដល់ក្រុមហ៊ុនដែលបានអនុវត្តតាមច្បាប់ និងក្រុមហ៊ុនដែលចង់អនុវត្តតាមច្បាប់ពន្ធដារ អង្គការតម្លាភាពកម្ពុជាបានផ្តួចផ្តើមបង្កើតនូវ "ករណីសិក្សាស្តីពីប្រព័ន្ធពន្ធដារ" ដែលមានគោលបំណងរកឲ្យឃើញនូវ បញ្ហាគន្លឹះនៅក្នុងបរិយាកាសពន្ធដារនៅប្រទេសកម្ពុជា និងដំណោះស្រាយដែលអាចអនុវត្តបានសម្រាប់ការកែលម្អ។ របកគំហើញនៃការស្រាវជ្រាវនេះនឹងផ្តល់ជាមូលដ្ឋានដ៏សំខាន់ដើម្បីបង្កើតជាអនុសាសន៍សម្រាប់រដ្ឋាភិបាល ក្រុមហ៊ុន និងសង្គមស៊ីវិលក្នុងការកាត់បន្ថយការប្រព្រឹត្តអំពើពុករលួយ នៅក្នុងប្រព័ន្ធពន្ធដារដែលជះឥទ្ធិពលទៅលើវិស័យឯកជននៅកម្ពុជា។

## ២. គោលបំណងនៃការសិក្សាស្រាវជ្រាវ

គោលបំណងនៃករណីសិក្សានេះមាន៣ផ្នែក ៖ (១) ពិពណ៌នាអំពីបរិយាកាសពន្ធដារនៅប្រទេសកម្ពុជាដោយផ្អែកលើទស្សនៈប្រឆាំងអំពើពុករលួយ (២) ចង្អុលបង្ហាញ និងវិភាគអំពីបទពិសោធន៍ផ្សេងៗពាក់ព័ន្ធនឹងអំពើពុករលួយដែលក្រុមហ៊ុនជួបប្រទះ និងផលប៉ះពាល់នៃអំពើពុករលួយមកលើប្រព័ន្ធពន្ធដារ និង (៣) ផ្តល់អនុសាសន៍សំខាន់ៗដើម្បីកែលម្អប្រព័ន្ធពន្ធដារនៅកម្ពុជាដោយផ្អែក លើព័ត៌មានត្រឡប់ពីវិស័យឯកជន។

ដើម្បីសម្រេចនូវគោលបំណងទាំងនេះ ការវិភាគនៃការសិក្សាស្រាវជ្រាវនេះបានប្រើប្រាស់នូវវិធីសិក្សាដោយផ្អែកលើការរុករក ដើម្បីធ្វើការស៊ើបអង្កេតក្រុមហ៊ុនឯកជន និងអ្នកផ្តល់សេវាកម្មពន្ធ (ទីប្រឹក្សាយោបល់ខាងផ្នែកពន្ធដារ) សមាគមពាណិជ្ជកម្ម និងមន្ត្រីរដ្ឋាភិបាល។ ករណីសិក្សានេះស្រាវជ្រាវពីការយល់ឃើញរបស់ក្រុមហ៊ុនឯកជនលើប្រព័ន្ធពន្ធដារដោយជីកកកាយ ពីការអនុវត្តក្នុងការបង់ពន្ធផ្ទាល់ជាមួយនឹងមន្ត្រីពន្ធដារ រួមមានទាំងទិដ្ឋភាពវិជ្ជមាន និងអវិជ្ជមាននៃនីតិវិធីសារពើពន្ធ។ ការសិក្សានេះក៏ធ្វើការស្រាវជ្រាវពីលទ្ធផលនៃកំណែទម្រង់ប្រព័ន្ធពន្ធដារនាពេលថ្មីៗ និងមូលហេតុសំខាន់មួយចំនួននៃការប្រព្រឹត្តអំពើពុករលួយក្នុងប្រព័ន្ធពន្ធដារដែលវិស័យឯកជនបានជួបប្រទះផងដែរ។ ការសិក្សាស្រាវជ្រាវ នឹងប្រើរបកគំហើញដែលរកឃើញក្នុងការស្វែងរកដំណោះស្រាយ និងអនុសាសន៍ សម្រាប់រដ្ឋាភិបាលធ្វើការពិចារណាដើម្បីធ្វើឲ្យប្រព័ន្ធពន្ធដារ និងបរិយាកាសធុរកិច្ចនៅកម្ពុជាកាន់តែល្អប្រសើរឡើង។ ការធ្វើកំណែទម្រង់ប្រព័ន្ធពន្ធដារ និងបរិយាកាសធុរកិច្ចនៅកម្ពុជានឹងនាំឲ្យមានការប្រកួតប្រជែង និងបរិយាកាសវិនិយោគដ៏ល្អប្រសើរជាក់ជាមិនខាន។

របាយការណ៍នៃការសិក្សាស្រាវជ្រាវនេះចែកចេញជា ៦ផ្នែក៖

១. ការសិក្សាលើឯកសារពាក់ព័ន្ធនានា

២. វិធីសាស្ត្រនៃការសិក្សា

៣. សេចក្តីសង្ខេបអំពីប្រព័ន្ធពន្ធដារនៅកម្ពុជា

៤. បរិយាកាសពន្ធដារដោយផ្អែកលើទស្សនៈប្រឆាំងអំពើពុករលួយ

៥. មូលហេតុ និងផលប៉ះពាល់នៃអំពើពុករលួយលើប្រព័ន្ធពន្ធដារនៅកម្ពុជា និង

៦. សេចក្តីសន្និដ្ឋាន និងអនុសាសន៍។

## ៣. ការសិក្សាលើឯកសារពាក់ព័ន្ធនានា

ការសិក្សាលើឯកសារពាក់ព័ន្ធនានា មានគោលបំណងស្វែងរកនូវនិយមន័យនៃពាក្យគន្លឹះ ដែលចាំបាច់បំផុតចំពោះរបកគំហើញរបាយការណ៍ ពាក្យទាំងនោះរួមមាន៖ (i) អំពើពុករលួយ (ii) អ្នកជាប់ពន្ធតាមរបបម៉ៅការ (iii) អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស (iv) ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ (v) ពន្ធកាត់ទុក (vi) អាករលើតម្លៃបន្ថែម (vii) ពន្ធប៉ាតង់ និង (viii) ពន្ធលើប្រាក់បៀវត្ស។

- **អំពើពុករលួយ:** គឺជាការរំលោភបំពានលើអំណាច ដែលផ្តល់ឲ្យដើម្បីផលប្រយោជន៍ឯកជន[7]។ ធនាគារពិភពលោកបានចាត់ទុកអំពើពុករលួយ គឺជាការរំលោភបំពាននូវមុខតំណែងសាធារណៈ ដើម្បីទទួលបានផលប្រយោជន៍ផ្ទាល់ខ្លួន[8]។
- **អ្នកជាប់ពន្ធតាមរបបម៉ៅការ:** សំដៅលើអាជីកម្មទាំងឡាយណា ដែលមានផលរបរប្រចាំឆ្នាំទាបជាងអាជីវកម្ម ដែលជាប់ពន្ធតាមរបបស្វ័យប្រកាស ដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ ។ អ្នកជាប់ពន្ធលើប្រាក់ចំណេញដែលស្ថិតក្នុងប្រព័ន្ធពន្ធដារតាមរបបម៉ៅការ ត្រូវបង់ពន្ធរៀងរាល់ខែនៅពេលណាមួយដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ។ អ្នកជាប់ពន្ធរបបម៉ៅការ បង់ពន្ធជូនមន្ត្រីពន្ធដារដែលមកប្រមូលពន្ធរៀងរាល់ខែ។ ផលវិបាកគឺ រដ្ឋាភិបាលរកឃើញថាការប្រមូលពន្ធតាមប្រភេទរបបនេះមានបញ្ហាប្រឈម ដូច្នេះរដ្ឋាភិបាលបានសម្រេចលុបចោលពន្ធតាមរបបម៉ៅការ ចេញពីប្រព័ន្ធពន្ធដារចាប់តាំងពីដើមឆ្នាំ២០១៦។
- **អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស:** ចាប់តាំងពីដើមឆ្នាំ២០១៦មក អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស សំដៅដល់អាជីវកម្មទាំងឡាយណា ដែលមានផលរបរប្រចាំឆ្នាំច្រើនប្រមាណជាង២៥០លានរៀល ហើយអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវបានបែងចែកជា ៣ប្រភេទ៖ អ្នកជាប់ពន្ធតូច អ្នកជាប់ពន្ធមធ្យម អ្នកជាប់ពន្ធធំ អាស្រ័យទៅលើផលរបរប្រចាំឆ្នាំរបស់ពួកគេ[9]។

[7]អង្គការតម្លាភាពអន្តរជាតិ តើអំពើពុករលួយគឺជាអ្វី?អាចរកបាននៅ:http://bit.ly/2hk4wqT.

[8]ក្រុមធនាគារពិភពលោក ជួយប្រទេសនានាប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ: តួនាទីរបស់ធនាគារពិភពលោក អាចរកបាននៅ:http://bit.ly/1G8kxVo.

[9]ប្រសាសន៍របស់ ឯ.ឧ. គង់ វិបុល អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ(GDT)ក្នុងកិច្ចសម្ភាសន៍ជាមួយនឹងទូរទស្សន៍បាយ័ន នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦។សូមមើលត្រង់ចំណុច៥.២ ការចុះបញ្ជីពន្ធដារនៃរបាយការណ៍នេះសម្រាប់ព័ត៌មានលំអិតស្តីពីអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស។

- **ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ:** រាល់អ្នកជាប់ពន្ធដែលជាប់កាតព្វកិច្ចត្រូវបង់ពន្ធលើប្រាក់ចំណេញរៀងរាល់ខែ តាមអត្រាមួយភាគរយ(១%) នៃផលរបរ រួមបញ្ចូលពន្ធគ្រប់ប្រភេទ លើកលែងតែអាករលើតម្លៃបន្ថែម។ ប្រាក់រំដោះពន្ធលើប្រាក់ចំណេញនេះ ត្រូវដកចេញពីពន្ធលើប្រាក់ចំណេញនៅពេលជម្រះបញ្ជីពន្ធប្រចាំឆ្នាំ[10]។
- **ពន្ធកាត់ទុក:** ជាទូទៅត្រូវបានកំណត់ថាអ្នកបង់ពន្ធជា និវាសនជន ដែលបានចំណូលពីអត្រាការប្រាក់ ប្រាក់សួយសារ និងចំណូលដែលទាក់ទងនឹងការប្រើប្រាស់ ទ្រព្យសម្បត្តិ ភាគលាភ និងប្រាក់ចំណូលដែលបានទទួលពីការបំពេញសេវាកម្មបច្ចេកទេស ឬគ្រប់គ្រងរបស់បុគ្គលអនិវាសនជន ត្រូវកាត់ទុក និងបង់នូវប្រាក់ពន្ធចំនួន១៤ភាគរយ។ ពន្ធកាត់ទុកត្រូវដល់កាលកំណត់នៅពេលណាមួយដែលការបង់ប្រាក់ត្រូវបានធ្វើឡើង ឬនៅពេលដែលការចំណាយត្រូវបានកត់ត្រាទុក។ ប្រាក់ដែលទូទាត់ឲ្យបុគ្គល និវាសនជនត្រូវជាប់ពន្ធកាត់ទុកតាមអត្រា ដូចខាងក្រោម៖
  - ជួល (១០%)
  - ការប្រាក់ (១៥% លើកលែងតែការបង់ប្រាក់ទៅឲ្យស្ថាប័នហិរញ្ញវត្ថុក្នុងស្រុក)
  - សេវាកម្ម (១៥% លើកលែងតែការបង់ប្រាក់ទៅឲ្យអ្នកជាប់ពន្ធដែលបានចុះបញ្ជីដែលមានវិក្កយប័ត្រមានអាករលើតម្លៃបន្ថែម) និង
  - ប្រាក់សួយសារ (១៥%)

ពន្ធកាត់ទុក មិនត្រូវអនុវត្តចំពោះការប្រាក់ដែលត្រូវបង់ទៅឲ្យធនាគារ ឬស្ថាប័នសញ្ជ័យធនក្នុងស្រុក ឬប្រាក់ចំណូលលើកលែងពន្ធ[11]។

- **អាករលើតម្លៃបន្ថែម:** ជាទូទៅ អាករលើតម្លៃបន្ថែមជាបន្ទុករបស់អ្នកប្រើប្រាស់ ឬអាជីវកម្មដែលមានការលើកលែងពន្ធ ខណៈដែលគេមិនអាចទទួលបានមកវិញនូវតម្លៃពន្ធដែលបានបង់រួចហើយ។ អាស្រ័យតាមប្រព័ន្ធពន្ធដារលើតម្លៃបន្ថែមនៅកម្ពុជា លទ្ធផលពន្ធប្រមូលបានពីអតិថិជន ដោយបូកបន្ថែមអាករលើតម្លៃបន្ថែមទៅលើចំនួនដែលត្រូវគិតចំពោះទំនិញ ឬសេវាកម្ម។ ទោះបីជាយ៉ាងណាក៏ដោយ អាជីវកម្មមួយក៏ត្រូវទូទាត់ពន្ធដែលបានដាក់បញ្ចូលទៅឲ្យអ្នកផ្គត់ផ្គង់លើការទិញដែលបានធ្វើឡើង។ អត្រានៃអាករលើតម្លៃបន្ថែមមានដូចខាងក្រោម៖
  - 0% អត្រានេះអនុវត្តចំពោះតែទំនិញនាំចេញពីព្រះរាជាណាចក្រកម្ពុជា និងសេវាកម្មដែលប្រើប្រាស់នៅក្រៅប្រទេសកម្ពុជា។ ការនាំចេញកំណត់ថាជាការដឹកជញ្ជូនដោយរួមបញ្ចូលទាំងអ្នកដំណើរ និងទំនិញជាអន្តរជាតិ ។

---

[10]អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ អាចរកបាននៅ:http://bit.ly/2hjODUp.

[11]ក្រុមហ៊ុន Bun & Associates, មគ្គុទ្ទេសន៍ណែនាំ អំពីប្រព័ន្ធពន្ធដារនៅកម្ពុជាឆ្នាំ២០១៤ អាចរកបាននៅ:http://bit.ly/2gByFnm.

- ១០% អត្រាស្តង់ដានេះអនុវត្តចំពោះគ្រប់ការផ្គត់ផ្គង់ទាំងអស់ជាជាងការនាំចេញ និងការផ្គត់ផ្គង់មិនជាប់ពន្ធផង[12]។

- **ពន្ធប៉ាតង់:** គឺជាពន្ធប្រចាំឆ្នាំ ដែលត្រូវបានកំណត់លើសកម្មភាពអាជីវកម្មដោយផ្អែកលើប្រភេទអ្នកជាប់ពន្ធ និងកម្រិតផលរបរដែលតម្រូវឲ្យគ្រប់ក្រុមហ៊ុនដែលប្រកបអាជីវកម្មនៅក្នុងប្រទេសកម្ពុជាទាំងអស់បង់នៅត្រឹមចុងខែមីនាជារៀងរាល់ឆ្នាំ។ អ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្មច្រើន ត្រូវបង់ពន្ធប៉ាតង់ផ្សេងគ្នាទៅតាមសកម្មភាពអាជីវកម្មនីមួយៗ។ យោងតាមប្រកាសលេខ១៨២១ ស្តីពី "នីតិវិធីសម្រាប់ការគ្រប់គ្រងការប្រមូលពន្ធប៉ាតង់" ។ បែបបទនៃការបង់ពន្ធប៉ាតង់ត្រូវបានកំណត់ និងបែងចែកដូចតទៅ៖ ៤០០ ០០០៛ សម្រាប់អ្នកជាប់ពន្ធតូច ១ ២០០ ០០០៛ សម្រាប់អ្នកជាប់ពន្ធមធ្យម និងត្រូវបង់ពី ៣ ០០០ ០០០៛ ទៅ ៥ ០០០ ០០០៛ សម្រាប់អ្នកជាប់ពន្ធធំ។ អ្នកជាប់ពន្ធត្រូវមានកាតព្វកិច្ច ដាក់តាំងបង្ហាញប័ណ្ណប៉ាតង់ដែលមានសុពលភាពនៅតាមទីតាំងប្រកបអាជីវកម្មរបស់ខ្លួន[13]។
- **ពន្ធលើប្រាក់បៀវត្ស:** ប្រាក់បៀវត្សរបស់និយោជិតនិវាសនជន ត្រូវជាប់ពន្ធលើប្រាក់បៀវត្សដែលទទួលបានពីប្រភពកម្ពុជា និងបរទេសតាមអត្រាកំណើនពី០% ទៅ២០%ក្នុងមួយខែ និងនិយោជិតអនិវាសនជនត្រូវជាប់ពន្ធតាមអត្រាថេរមួយគឺ ២០%នៃប្រាក់បៀវត្សដែលទទួលបានពីប្រភពកម្ពុជាតែប៉ុណ្ណោះ។ ប្រាក់ខែត្រូវបានកំណត់ថាជាប្រាក់បំណាច់ប្រាក់ឈ្នួល ប្រាក់រង្វាន់ ប្រាក់ថែមម៉ោង ប្រាក់សំណង ប្រាក់អត្ថប្រយោជន៍ផ្ទាល់ ឬប្រាក់អត្ថប្រយោជន៍មិនផ្ទាល់ ឬប្រាក់បើកមុនដោយនិយោជក[14] ។ មូលដ្ឋានពន្ធត្រូវដកវិញចំនួន ៧៥ ០០០៛ ក្នុងមួយខែសម្រាប់កូន ឬប្រពន្ធស្ថិតក្នុងបន្ទុករបស់អ្នកជាប់ពន្ធនៅក្នុងស្រុក[15]។

***រូបភាពទី១ តារាងខាងក្រោមបង្ហាញពីអត្រាពន្ធលើប្រាក់បៀវត្សតាមអត្រាកំណើនពី០%ទៅ២០%***

ប្រាក់បៀវត្សប្រចាំខែ

| **គិតជាប្រាក់រៀល(៛)** | **គិតជាដុល្លារ ($)** | **អត្រា** |
|---|---|---|
| ០ – ៨០០ ០០០ | ០ – ២០០ | ០% |
| ៨០០ ០០១ – ១ ២៥០ ០០០ | ២០០ – ៣១២,៥០ | ៥% |
| ១ ២៥០ ០០១ – ៨ ៥០០ ០០០ | ៣១២,៥០ – ២ ១២៥ | ១០% |

[12]ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រកាសស្តីពីការអនុវត្តអាករលើតម្លៃបន្ថែម(VAT)ដើម្បីគាំទ្រឧស្សាហកម្ម ឬអ្នកម៉ៅការដែលផ្គត់ផ្គង់ទំនិញ ឬសេវាកម្មសម្រាប់បម្រើឲ្យការនាំចេញនៃឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ ឧស្សាហកម្មផលិតស្បែកជើង ឧស្សាហកម្មផលិតកាបូបស្ពាយ និងកាបូបដៃ និងឧស្សាហកម្មផលិតមួក តាមប្រកាសលេខ៣១១ សហវ/ប្រក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ អាចរកបាននៅ:http://bit.ly/2hCtxwR.

[13]ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រកាសស្តីពីនីតិវិធីនៃការគ្រប់គ្រងការប្រមូលពន្ធប៉ាតង់ លេខ១៨២១ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ អាចរកបាន:http://bit.ly/2gTBU7s.

[14] Id.

[15]អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រកាសស្តីពីពន្ធលើប្រាក់ចំណេញ លេខ១០៥៩ សហវ.ប្រក.ពដ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ អាចរកបាននៅ:http://bit.ly/2hjKNe0.

| | | |
|---|---|---|
| ៨ ៥០០ ០០១ – ១២ ៥០០ ០០០ | ២ ១២៥ – ៣ ១២៥ | ១៥% |
| ១២ ៥០០ ០០១ –ឡើងទៅ | ៣ ១២៥ ឡើងទៅ | ២០% |

អត្រាប្តូរប្រាក់ ១ដុល្លារអាមេរិក = ៤ ០០០រៀល

# ៤. វិធីសាស្ត្រនៃការសិក្សា

ការសិក្សានេះប្រើប្រាស់នូវវិធីសាស្ត្រសិក្សាស្រាវជ្រាវបែបគុណភាព ដើម្បីទទួលបាននូវការយល់ដឹងស៊ីជម្រៅចំពោះបរិយាកាសពន្ធដោយផ្អែកលើទស្សនៈប្រឆាំងនឹងអំពើពុករលួយ និងសិក្សាលម្អិតពីភាពស្មុគស្មាញដែលមាននៅក្នុងច្បាប់ស្តីពីសារពើពន្ធនៅកម្ពុជា។ ដើម្បីបង្កើតឲ្យមានការយល់ដឹងអំពីបរិយាកាសពន្ធនៅកម្ពុជា ករណីសិក្សានេះ បានប្រើប្រាស់ទាំងទិន្នន័យចម្បង (Primary Data) និងទិន្នន័យដែលមានស្រាប់ (Secondary Data)។ ដើម្បីទទួលបាននូវទិន្នន័យបឋម ការវិភាគបានធ្វើដោយប្រើនូវវិធីសិក្សាដោយផ្អែកលើការរុករកក្នុងការស៊ើបអង្កេតម្ចាស់អាជីវកម្ម ឬអ្នកដឹកនាំកំពូលរបស់អាជីវកម្មនានា អ្នកផ្តល់សេវាកម្មពន្ធដារ (ទីប្រឹក្សា) និងសមាគមពាណិជ្ជកម្ម។ ការសិក្សានេះប្រមូលទិន្នន័យចម្បងបានពីក្រុមហ៊ុនចំនួន១២ទាំងក្រុមហ៊ុនតូច មធ្យម និងក្រុមហ៊ុនធំៗនៅកម្ពុជា តាមរយៈការសម្ភាសជាមួយនឹងម្ចាស់ក្រុមហ៊ុនដោយផ្ទាល់ និងដាច់ដោយឡែកពីគ្នា។ ការស្ទង់មតិបែបគុណភាពស្វែងយល់ពីការយល់ឃើញរបស់ម្ចាស់អាជីវកម្មលើវិស័យពន្ធ និងការប្រាស័យទាក់ទងរបស់ពួកគេជាមួយនឹងមន្ត្រីពន្ធដារ។ ជាងនេះទៅទៀត វិធីសាស្ត្រនេះក៏បានរុករកឃើញនូវលទ្ធផលចេញពីការធ្វើកំណែទម្រង់លើប្រព័ន្ធពន្ធដារនាពេលថ្មីៗនេះ ក៏ដូចជាបុព្វហេតុមួយចំនួនដែលនាំឲ្យមានអំពើពុករលួយនៅក្នុងប្រព័ន្ធពន្ធដារផងដែរ។ របកគំហើញសំខាន់ៗត្រូវបានប្រើប្រាស់ ដើម្បីបង្កើតជាអនុសាសន៍សម្រាប់រដ្ឋាភិបាល ដើម្បីពិចារណាក្នុងការកែលម្អប្រព័ន្ធពន្ធដារ និងបរិយាកាសអាជីវកម្មនៅកម្ពុជា។

# ៥. ប្រព័ន្ធពន្ធដារនៅកម្ពុជា

## ៥.១ ទិដ្ឋភាពទូទៅ

ពន្ធ គឺជាប្រភពចំណូលដ៏ធំមួយរបស់រាជរដ្ឋាភិបាលកម្ពុជា។ ចំណូលពីការប្រមូលពន្ធ គឺត្រូវប្រើប្រាស់ដើម្បីទ្រទ្រង់ដល់ការចំណាយរបស់រដ្ឋាភិបាលលើសេវាសាធារណៈនានា ដូចជាមន្ទីរពេទ្យ ផ្លូវ ព្រំដែន និងការការពារបេតិកភ័ណ្ឌ ប្រាក់បៀវត្សសម្រាប់មន្ត្រីរាជការស៊ីវិល ប្រាក់បៀវត្សសម្រាប់ទាហាន កងកម្លាំង ស្ពាន និងសាលារៀន ជាដើម[16]។

[16] រាល់ចំណូលពីការប្រមូលពន្ធនេះគឺត្រូវប្រើប្រាស់សម្រាប់ការពារជាតិ និងការអភិវឌ្ឍន៍ សម្រាប់ព័ត៌មានបន្ថែម អាចរកបាននៅ: http://bit.ly/2hk0wqD.

ចាប់តាំងពីដើមឆ្នាំ២០១៦មក គេឃើញមានការដាក់ចេញបទប្បញ្ញត្តិមួយចំនួនដែលមានបំណងធ្វើកំណែទម្រង់ ដូចជាការលុបចោលនូវពន្ធតាមរបបម៉ៅការ ការចែកប្រភេទអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសកំណែទម្រង់ នីតិវិធីនៃការចុះបញ្ជីពន្ធដារ ការកំណត់វិធានគណនេយ្យដែលមានលក្ខណៈសាមញ្ញសម្រាប់អ្នកជាប់ពន្ធតូច ការតម្លើងកម្រិតពន្ធលើប្រាក់បៀវត្សរ៍អប្បបរមា និងការអនុគ្រោះមិនយកអាករលើតម្លៃបន្ថែមលើសម្ភារៈឧស្សាហកម្ម ដែលបំពីឲ្យវិស័យស្រូវអង្ករ និងសេវាសាធារណៈ។

ទោះបីយ៉ាងណាក៏ដោយ យោងតាមប្រសាសន៍របស់ **ឯកឧត្តម គង់ វិបុល** អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារដែលបានធ្វើឡើងក្នុងខែកញ្ញា ឆ្នាំ២០១៦ថ្មីៗនេះ បានឲ្យដឹងថាអគ្គនាយកដ្ឋានពន្ធដារសម្រេចបាននូវការងារសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- ការលុបចោលការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះមួយចំនួន
- បានបញ្ចប់កិច្ចព្រមព្រៀងការយកពន្ធត្រួតគ្នាលើកទី១របស់កម្ពុជាជាមួយប្រទេសសិង្ហបុរី ដោយមានជំនួយ ពីនាយកដ្ឋានរតនាគាររបស់សហរដ្ឋអាមេរិកក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ
- ការលើកលែងពន្ធលើការផ្ទេរកម្មសិទ្ធរវាងសាច់ញាតិ
- បង្កើតគណៈកម្មាធិការសម្រុះសម្រួលសារពើពន្ធ
- ការចុះអង្កេតស្រាវជ្រាវសហគ្រាសតាមដងផ្លូវចាប់ផ្តើមពីខែសីហា ឆ្នាំ២០១៦ ដើម្បីផ្ទៀងផ្ទាត់ការអនុវត្តការបង់ពន្ធរបស់អាជីវកម្ម នៅរាជធានីភ្នំពេញ និងទូទាំងប្រទេសកម្ពុជា[17]។

ការវិនិយោគបន្ថែមរបស់អគ្គនាយកដ្ឋានក្នុងការធ្វើឲ្យប្រសើរឡើងនូវដំណោះស្រាយបច្ចេកទេស រួមមានដូចខាងក្រោម៖

- ការចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តកម្ម និងជម្រើសការបង់ពន្ធតាមប្រព័ន្ធស្វ័យប្រវត្តកម្ម
- ការធ្វើឲ្យកាន់តែមានវិជ្ជាជីវៈចំពោះសេវាកម្មនានានៅទីស្តីការអគ្គនាយកដ្ឋានពន្ធដារ
- ប្រព័ន្ធទិន្នន័យថ្មីដើម្បីគ្រប់គ្រងការប្រមូលពន្ធលើអចលនទ្រព្យ
- បង្កើតកម្មវិធីសម្រាប់ទាញប្រើក្នុងទូរស័ព្ទទំនើប ដើម្បីជួយអ្នកប្រើប្រាស់គ្រប់គ្រងពន្ធលើប្រាក់បៀវត្សរ៍ និងពន្ធលើយានយន្ត
- របាយការណ៍អេឡិចត្រូនិច (E-reports) ដើម្បីវាយតម្លៃការអនុវត្តការងាររបស់បុគ្គលិកនៃអគ្គនាយកដ្ឋានពន្ធដារ និង

[17] សន្ទរកថាបើករបស់ឯ.ឧ.គង់ វិបុល អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៦ ក្នុងកម្មវិធីរបស់សភាពាណិជ្ជកម្មសហភាពអឺរ៉ុប អាចរកបាននៅ៖http://bit.ly/2hnxp64.

- ប្រព័ន្ធវិក្កយប័ត្រតែមួយដើម្បីធានានូវតម្លាភាព និងលុបបំបាត់នូវឱកាសក្នុងការជួបគ្នារវាងអ្នកផ្តល់សេវា និងអ្នកទទួលសេវា[18]។

## ៥.២ ការចុះបញ្ជីពន្ធដារ

ក្រោយពីបានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម ឬ/និងក្រសួងផ្សេងទៀតដែលពាក់ព័ន្ធគ្រប់អ្នកជាប់ពន្ធ ត្រូវជាប់កាតព្វកិច្ចចុះបញ្ជីជាមួយនឹងរដ្ឋបាលសារពើពន្ធក្នុងរយៈពេល១៥ថ្ងៃនៃការចាប់ផ្តើមសកម្មភាពអាជីវកម្មរបស់ខ្លួន។ មុនឆ្នាំ២០១៦ អ្នកជាប់ពន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងអស់ ត្រូវបានបែងចែកជាពីរប្រភេទ គឺអ្នកជាប់ពន្ធរបបម៉ៅការ និងអ្នកជាប់ពន្ធរបបពិត (ជាធម្មតាសំដៅដល់អ្នកជាប់ពន្ធរបបស្វ័យប្រកាស) ។ អ្នកជាប់ពន្ធរបបម៉ៅការ សំដៅដល់អ្នកជាប់ពន្ធតូចដែលខុសពីអ្នកជាប់ពន្ធរបបស្វ័យប្រកាសដែលពន្ធត្រូវបានកំណត់ជាផ្លូវការសម្រាប់រយៈពេលមួយជាក់លាក់ក្នុងកំឡុងឆ្នាំនោះ។ អ្នកជាប់ពន្ធរបបស្វ័យប្រកាសសំដៅលើអ្នកដែលមានផលរបរប្រចាំឆ្នាំលើសពី៥០០លានរៀល (១២៥០០០ដុល្លារ) ពីការផ្គត់ផ្គង់ទំនិញ ឬ២៥០លានរៀល (៦២៥០០ ដុល្លារ) ពីការផ្គត់ផ្គង់សេវាកម្ម និង១២៥លានរៀល (៣១២៥០ដុល្លារ) ក្នុងករណីផលរបរជាប់ពន្ធបានមកពីកិច្ចសន្យារដ្ឋាភិបាល[19]។

ទោះបីជាយ៉ាងណាក៏ដោយ ក្នុងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០១៦ ដែលបានអនុម័តនាពេលថ្មីៗនេះ (ព្រះរាជក្រមលេខនស/រក/១២១៥/០១៦) មានការកែប្រែច្រើនលើច្បាប់ស្តីពីសារពើពន្ធ[20]។ របបពន្ធម៉ៅការ ត្រូវបានលុបចោល ហើយសហគ្រាសទាំងឡាយណាដែលមានផលរបរប្រចាំឆ្នាំជាមធ្យម តិចជាង២៥០លានរៀលមិនតម្រូវឲ្យបង់ពន្ធទេ។ អាជីវកម្មណាដែលមានផលរបរប្រចាំឆ្នាំលើសពី ២៥០លានរៀល នឹងត្រូវបង់ពន្ធលើតម្លៃបន្ថែម ត្រូវប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ ប្រមូល និងបង់ពន្ធកាត់ទុកជាក់ស្តែង និងត្រូវធ្វើសវនកម្មពន្ធដារ។ ទន្ទឹមនឹងនេះ ច្បាប់ថ្មីក៏មានការកែប្រែនូវពន្ធរបបពិតដោយចែកជាបីប្រភេទ អ្នកជាប់ពន្ធតូច មធ្យម និងធំ។

- *អ្នកជាប់ពន្ធតូច:* អាជីវកម្មដែលមានផលរបរប្រចាំឆ្នាំពី២៥០លានរៀល (៦២៥០០ដុល្លារ) ទៅ៧០០លានរៀល (១៧៥០០០ដុល្លារ)
- *អ្នកជាប់ពន្ធមធ្យម:* អាជីវកម្មដែលមានផលរបរប្រចាំឆ្នាំពី៧០០លានរៀល (១៧៥០០០ដុល្លារ) ទៅ២០០០លានរៀល (៥០០០០០ដុល្លារ)

---

[18]Id.
[19]ប្រសាសន៍របស់អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារដែលបានធ្វើក្នុងកិច្ចសម្ភាសន៍មួយអំពីនីតិវិធី និងដំណើរការនៃការចុះបញ្ជីពន្ធដារ អាចរកបានhttp://bit.ly/2hk0wqD.
[20]ច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០១៦ ព្រះរាជក្រម លេខ នស/រក/១២១៥/០៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥

- *អ្នកជាប់ពន្ធធំ:* អាជីវកម្មដែលមានផលរបរប្រចាំឆ្នាំលើសពី២០០០លានរៀល (៥០០០០០ ដុល្លារ) ឡើងទៅ ឬដែលបានចុះបញ្ជីជាគម្រោងវិនិយោគដែលមានលក្ខណៈត្រឹមត្រូវ។

រាល់អាជីវកម្មក្នុងស្រុក និងបរទេសទាំងអស់ដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់កាតព្វកិច្ច និងត្រូវគោរពអនុវត្តបទប្បញ្ញត្តិពន្ធដារដែលមានក្នុងច្បាប់ និងក្រមប្រតិបត្តិគណនេយ្យ រួមមានដូចខាងក្រោមៈ

- ការរៀបចំ និងការបង់ពន្ធប្រចាំខែ និងប្រចាំឆ្នាំ នឹងត្រូវបង់ពន្ធផ្សេងៗទៀតដូចជា៖
  - ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ
  - ពន្ធកាត់ទុក
  - អាករលើតម្លៃបន្ថែម
  - ពន្ធលើប្រាក់បៀវត្ស និងអត្ថប្រយោជន៍បន្ថែមផ្សេងៗ និង
  - ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ
- ត្រូវធ្វើសវនកម្មពន្ធដារ (ដូចជាសវនកម្មបឋម "ការហៅទូរស័ព្ទដើម្បីសួរនាំពីសំណាក់មន្ត្រីពន្ធដារ" ការធ្វើសវនកម្មមានកម្រិត និងការធ្វើសវកម្មទូលំទូលាយ)
- យោងតាមកាតព្វកិច្ចរបស់អ្នកជាប់ពន្ធដូចដែលបទប្បញ្ញត្តិពន្ធដារបានកំណត់ រួមទាំងការថែរក្សានូវរបាយការណ៍គណនេយ្យផងដែរ។

### ៥.២.១ អ្នកជាប់ពន្ធតូច

*ដំណើរការចុះបញ្ជីពន្ធដារ*

បន្ទាប់ពីចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម ឬក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ច អ្នកដាក់ពាក្យជាប់ពន្ធតូចត្រូវចុះបញ្ជីជាមួយនឹងការិយាល័យរដ្ឋបាលសារពើពន្ធដែលនៅជិតសហគ្រាសរបស់ខ្លួនបំផុត។ ការចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធត្រូវធ្វើឲ្យបានរួចរាល់ក្នុងរយៈពេល១៥ថ្ងៃ បន្ទាប់ពីបានប្រកាសសកម្មភាពអាជីវកម្មរបស់ខ្លួន បើមិនដូច្នេះទេ អ្នកដាក់ពាក្យនឹងត្រូវទទួលពិន័យ។ អ្នកដាក់ពាក្យអាចទៅទីស្នាក់ការរបស់អគ្គនាយកដ្ឋានពន្ធដារដោយផ្ទាល់ ឬអាចចូលទៅកាន់គេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារដើម្បីទាញយកពាក្យស្នើសុំចុះបញ្ជីពន្ធដារ។ បន្ទាប់មក អ្នកដាក់ពាក្យត្រូវៈ

- <u>ដំណាក់កាលទី១៖</u> បំពេញពាក្យស្នើសុំ

- <u>ដំណាក់កាលទី២៖</u> បញ្ជូនពាក្យស្នើសុំដែលបានបំពេញ រួចផ្ញើទៅអគ្គនាយកដ្ឋានពន្ធដារ ដោយភ្ជាប់ជាមួយនូវ[21]៖
  - វិញ្ញាបនបត្រដែលចេញឲ្យដោយក្រសួងពាណិជ្ជកម្ម ឬក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ច (ប្រសិនបើមាន)
  - អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនដែលមានសុពលភាព
  - រូបថត១សន្លឹករបស់ម្ចាស់អាជីវកម្ម ទំហំ ៣៥ គុណនឹង ៤៥ មីលីម៉ែត្រ
  - ប័ណ្ណកម្មសិទ្ធកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំង (ប្រសិនបើមាន)
  - វិក្កយប័ត្រពន្ធអចលនទ្រព្យ (ប្រសិនបើមាន)
  - លិខិតដែលចេញដោយក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ច (ប្រសិនបើមាន)
- <u>ដំណាក់កាលទី៣៖</u> បង់ពន្ធប៉ាតង់ និងពន្ធចុះបញ្ជីនៅតាមធនាគារណាមួយបន្ទាប់ទទួលបាននូវលេខអាករលើតម្លៃបន្ថែម VAT TIN ដែលទទួលបានពីអគ្គនាយកដ្ឋានពន្ធដារ និង[22]
- <u>ដំណាក់កាលទី៤៖</u> បញ្ជូនវិក្កយប័ត្រនៃពន្ធប៉ាតង់ និងអាករចុះបញ្ជីដែលចេញឲ្យ ដោយធនាគារទៅឲ្យមន្ត្រីពន្ធដារ ដើម្បីបំពេញដំណើរការសុំចុះបញ្ជីបង្ហើយ។

[21]រាល់ឯកសារភ្ជាប់ត្រូវបញ្ជាក់ដោយមន្ត្រីពន្ធដារដែលទទួលខុសត្រូវ ឬដោយក្រសួង/ស្ថាប័នមានសមត្ថកិច្ច

[22]មានស្ថាប័នហិរញ្ញវត្ថុចំនួន៥ស្ថាប័នដែលទទួលបានសិទ្ធដើម្បីប្រមូលពន្ធឲ្យអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករ។ ស្ថាប័នទាំងនេះមាន ធនាគារអេស៊ីលីដា ធនាគារកាណាឌីយ៉ា ធនាគារកម្ពុជាសាធារណៈ ធនាគារវឌ្ឍនៈ(ចាប់ពីដើមឆ្នាំ២០១៧) និង ធនាគារឯកទេសរីង។

*រូបភាពទី២ ដំណើរការចុះបញ្ជីពន្ធដារ*




## ថ្លៃចុះបញ្ជីពន្ធដារ

នៅដំណាក់កាលទី៣ អ្នកដាក់ពាក្យជាប់ពន្ធតូច ត្រូវតម្រូវឲ្យបង់ថ្លៃសេវា និងថ្លៃអាករដូចខាងក្រោម៖

- ថ្លៃសេវានៃការចុះបញ្ជី ចំនួន២០០០០៛ (៥ដុល្លារ)
- អាករចុះបញ្ជី ចំនួន១០០០០០០៛ (២៥០ដុល្លារ)
- ពន្ធប៉ាតង់ ចំនួន៤០០០០០៛ (១០០ដុល្លារ)

## កាតព្វកិច្ចរបស់អ្នកជាប់ពន្ធតូច

រាល់អ្នកជាប់ពន្ធតូចត្រូវបំពេញកាតព្វកិច្ចដូចខាងក្រោម:

- កាតព្វកិច្ចប្រចាំខែ: ត្រូវរៀបចំរបាយការណ៍គណនេយ្យសាមញ្ញមួយ (កត់ត្រានូវការលក់ ការចំណាយ និងសារពើភ័ណ្ឌ) និងបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ពន្ធលើប្រាក់បៀវត្ស អាករស្នាក់នៅ និង២០%នៃតម្លៃអាករលើតម្លៃបន្ថែម។[23]
- កាតព្វកិច្ចប្រចាំឆ្នាំ: អ្នកជាប់ពន្ធតូចមានកាតព្វកិច្ចៈ
    - ប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំជាមួយ នឹងអគ្គនាយកដ្ឋានពន្ធដារនៅត្រឹមចុងខែមីនាបន្ទាប់ពីឆ្នាំសារពើពន្ធ និង
    - ប្រកាសពន្ធ និងបង់ពន្ធប៉ាតង់រៀងរាល់ឆ្នាំនៅចុងខែមីនា

### ៥.២.២ អ្នកជាប់ពន្ធមធ្យម និងធំ

*ដំណើរការចុះបញ្ជីពន្ធដារ*

ស្រដៀងគ្នានឹងអ្នកជាប់ពន្ធតូចដែរ អ្នកដាក់ពាក្យដែលជាប់ពន្ធមធ្យម និងពន្ធធំ ត្រូវចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ក្នុងរយៈពេល១៥ថ្ងៃបន្ទាប់ពីបានប្រកាសធ្វើសកម្មភាពអាជីវកម្មរបស់ខ្លួន។ អ្នកដាក់ពាក្យអាចទៅទីស្នាក់ការរបស់អគ្គនាយកដ្ឋានពន្ធដារដោយផ្ទាល់ ឬអាចចូលទៅកាន់គេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីទាញយកពាក្យស្នើសុំចុះបញ្ជីពន្ធដារ។ បន្ទាប់មក អ្នកដាក់ពាក្យត្រូវៈ

- ដំណាក់កាលទី១៖ បំពេញពាក្យស្នើសុំ[24]
- ដំណាក់កាលទី២៖ បញ្ជូនពាក្យស្នើសុំដែលបានបំពេញហើយនោះ ទៅអគ្គនាយកដ្ឋានពន្ធដារដោយភ្ជាប់ជាមួយនូវ៖[25]
    - វិញ្ញាបនបត្រដែលចេញឲ្យដោយក្រសួងពាណិជ្ជកម្ម ឬក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ច (ប្រសិនបើមាន) ច្បាប់ដើម
    - លក្ខន្តិកៈក្រុមហ៊ុន ច្បាប់ដើម
    - លិខិតបញ្ជាក់ពីការដាក់ដើមទុននៅធនាគារ
    - អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន
    - សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ
    - លិខិតបញ្ជាក់ទីលំនៅដែលចេញដោយអាជ្ញាធរមូលដ្ឋាន ច្បាប់ដើម
    - រូបថត១សន្លឹក ទំហំ ៣៥ គុណនឹង ៤៥របស់ក្រុមប្រឹក្សាភិបាល ម្ចាស់ភាគហ៊ុន ឬតំណាងដែលទទួលសិទ្ធពីប្រធានក្រុមប្រឹក្សាភិបាល ថតថ្មីៗ ច្បាប់ដើម
    - លិខិតបញ្ជាក់កម្មសិទ្ធប្លង់ដីធ្លី ឬកិច្ចសន្យាជួលទីតាំង (ប្រសិនបើមាន)

[23] វាជាករណីពិសេសសម្រាប់អ្នកជាប់ពន្ធតូច ហើយពួកគេត្រូវបង់តែ២០%នៃតម្លៃVATទៅឲ្យរដ្ឋាភិបាលប៉ុណ្ណោះ។

[24] សូមមើលការបំពេញទម្រង់ស្នើសុំចុះបញ្ជីតាមរយៈhttps://www.youtube.com/watch?v=ufNp2frmklg

[25] រាល់ឯកសារភ្ជាប់ត្រូវបញ្ជាក់ដោយមន្ត្រីពន្ធដារដែលទទួលខុសត្រូវ ឬដោយក្រសួង/ស្ថាប័នមានសមត្ថកិច្ច

- ◦ របាយការណ៍ពន្ធអចលនទ្រព្យ ឬវិក្កយប័ត្រពន្ធអចលនទ្រព្យ (ប្រសិនបើមាន)
- ◦ លិខិតបញ្ជាក់ដែលចេញដោយក្រុមប្រឹក្សាវិនិយោគកម្ពុជា ឬក្រុមប្រឹក្សាតំបន់សេដ្ឋកិច្ចពិសេស ឬអនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត (គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់)
- ◦ លិខិតដែលចេញឲ្យដោយក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ច (ប្រសិនបើមាន)

- <u>ដំណាក់កាលទី៣៖</u> បង់ពន្ធប៉ាតង់ និងពន្ធចុះបញ្ជីនៅតាមធនាគារណាមួយ បន្ទាប់ពីទទួលបាននូវលេខអាករលើតម្លៃបន្ថែមដែលទទួលបានពីអគ្គនាយកដ្ឋានពន្ធដារ និង
- <u>ដំណាក់កាលទី៤៖</u> បញ្ជូនវិក្កយប័ត្រនៃពន្ធប៉ាតង់ និងអាករចុះបញ្ជី ដែលចេញឲ្យដោយធនាគារ ទៅឲ្យមន្ត្រីពន្ធដារ ដើម្បីបំពេញដំណើរការសុំចុះបញ្ជីបង្ហើយ។

## *ថ្លៃចុះបញ្ជីពន្ធដារ*

អ្នកដាក់ពាក្យជាប់ពន្ធមធ្យម និងធំតម្រូវឲ្យបង់ថ្លៃសេវា និងថ្លៃអាករ ដូចខាងក្រោម៖

- ថ្លៃសេវានៃការចុះបញ្ជី ចំនួន ៤០០ ០០០៛ (១០០ដុល្លារ)
- អាករចុះបញ្ជី ចំនួន ១ ០០០ ០០០៛ (២៥០ដុល្លារ)
- ពន្ធប៉ាតង់ ចំនួន ១ ២០០ ០០០៛ (៣០០ដុល្លារ) សម្រាប់អ្នកជាប់ពន្ធមធ្យម និងចន្លោះពីចំនួន ៣ ០០០ ០០០៛ (៧៥០ដុល្លារ) ទៅចំនួន ៥ ០០០ ០០០៛ (១ ២៥០ដុល្លារ) សម្រាប់អ្នកជាប់ពន្ធធំ។

## *កាតព្វកិច្ចរបស់អ្នកជាប់ពន្ធមធ្យម និងពន្ធធំ*

រាល់អ្នកជាប់ពន្ធមធ្យម និងពន្ធធំទាំងអស់ ត្រូវជាប់កាតព្វកិច្ចប្រកាសរបាយការណ៍សារពើពន្ធ ទោះបីជាគេមិនប្រតិបត្តិការក្នុងខែឬឆ្នាំដែលបានគ្រោងទុក ប៉ុន្តែមិនទាន់ចាប់ផ្តើមដែលអាចរាយការណ៍បាន ឬមិនទាន់បានបង់ពន្ធប្រចាំខែ ឬពន្ធប្រចាំឆ្នាំក៏ដោយ។

- <u>កាតព្វកិច្ចប្រចាំខែៈ</u> ត្រូវបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ពន្ធលើប្រាក់បៀវត្ស អាករស្នាក់នៅ និង២០%នៃតម្លៃអាករលើតម្លៃបន្ថែម និងពន្ធដទៃទៀតក្នុងន័យពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ ទំនិញ និងសេវាកម្ម
- <u>កាតព្វកិច្ចប្រចាំឆ្នាំៈ</u> អ្នកជាប់ពន្ធមធ្យម និងពន្ធធំ មានកាតព្វកិច្ច៖
    - ◦ ប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ជាមួយនឹងអគ្គនាយកដ្ឋានពន្ធដារត្រឹមចុងខែមីនា បន្ទាប់ពីឆ្នាំសារពើពន្ធ និង

- ប្រកាសពន្ធ និងបង់ពន្ធប៉ាតង់រៀងរាល់ឆ្នាំនៅចុងខែមីនា

## ៥.៣ ការកែទម្រង់នានាពេលថ្មីៗចំនុះរបស់អគ្គនាយកដ្ឋានពន្ធដារ

### ៥.៣.១ ការលុបចោលនូវពន្ធកាត់ទុកលើអត្ថប្រយោជន៍បន្ថែមសម្រាប់អាជីវកម្មទាំងអស់

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកាលពីថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៦ បានចេញសារាចរលេខ០១១សហវ ស្តីពី "ការអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធលើអត្ថប្រយោជន៍បន្ថែម"។ សារាចរនេះ អនុវត្តចំពោះគ្រប់អាជីវកម្មទាំងអស់ និងពិពណ៌នាអំពីអត្ថប្រយោជន៍របស់និយោជិតជាប្រាក់ជាក់ស្តែង ឬអត្ថប្រយោជន៍មិនមែនសាច់ប្រាក់ដែលមិនត្រូវជាប់ពន្ធលើអត្ថប្រយោជន៍បន្ថែមនោះ។[26]

### ៥.៣.២ ការចុះពិនិត្យមើលគ្រប់សហគ្រាសទាំងអស់(ទាំងចុះបញ្ជី និងមិនចុះបញ្ជី)នៅកម្ពុជា

ជាផ្នែកមួយនៃដំណើរការកំណែទម្រង់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញសេចក្តីប្រកាសមួយលេខ ០៣៩ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៦ ស្តីពី "ការចុះទស្សនកិច្ចតាមសហគ្រាសដើម្បីប្រមូលព័ត៌មានអាជីវកម្មនៅរាជធានីភ្នំពេញដើម្បីកែតម្រូវការចុះបញ្ជីពន្ធដារ"។[27] នៅខែសីហា ឆ្នាំ២០១៦ ការចុះទស្សនកិច្ចតាមសហគ្រាស ឬការចុះស្ទង់មតិសហគ្រាសតាមដងផ្លូវ បានធ្វើឡើងនៅរាជធានីភ្នំពេញ។[28] ការស្ទង់មតិនេះ ធ្វើការវាយតម្លៃលើស្ថិតិរបស់សហគ្រាស កំណត់ថាតើអាជីវកម្មទាំងនោះបានអនុវត្តតាមកាតព្វកិច្ច ដែលតម្រូវឲ្យ "ចុះបញ្ជីឡើងវិញ" ដោយយោងតាមប្រកាសលេខ៤៩៦ស្តីពីការចុះបញ្ជីពន្ធដារដែរឬទេ និងធ្វើឲ្យប្រាកដថាអាជីវកម្មនីមួយៗបានបំពេញកាតព្វកិច្ច និងលើកឡើងនូវបញ្ហាពាក់ព័ន្ធ។ មុនពេលទស្សនកិច្ចគ្រប់ ម្ចាស់អាជីវកម្មត្រូវបានជូនដំណឹង ដើម្បីត្រៀមរៀបចំឯកសារចាំបាច់នានាឲ្យបានស្រេច។[29]

### ៥.៣.៣ ការកែប្រែកម្រិតពន្ធលើប្រាក់បៀវត្សរ៍អប្បរមា

កម្រិតប្រាក់បៀវត្សអប្បរមាចាប់ផ្តើមបង់ពន្ធបានកែប្រែពី ៨០០ ០០០៛ (២០០ដុល្លារ) ទៅ ១ ០០០ ០០១៛ (ប្រហែល ២៥០ដុល្លារ) ចាប់អនុវត្តពីខែមករា ឆ្នាំ២០១៧មក។ ដូច្នេះ អ្នកដែលមានប្រាក់ខែចាប់ពី ១ ០០០ ០០១៛ ទៅត្រូវជាប់កាតព្វកិច្ចបង់ពន្ធលើប្រាក់បៀវត្ស។ ប៉ុន្តែប្រាក់ខែទាបជាង ១ ០០០ ០០១៛ នឹងមិនជាប់កាតព្វកិច្ចបង់ពន្ធលើប្រាក់បៀវត្សឡើយ។[30]

[26]ព្រឹត្តិបត្រអំពីបច្ចុប្បន្នភាពពន្ធដារកម្ពុជារបស់ក្រុមហ៊ុន VDB/Loi, ការវិវត្តន៍ចុងក្រោយនៃពន្ធលើអត្ថប្រយោជន៍ផ្សេងៗអាចរកបាននៅ:http://bit.ly/2gC4lsD.
[27]ក្រុមហ៊ុនSciaroni& Associates, សេចក្តីជូនដំណឹង លេខ:០៣៩ ស្តីពីអគ្គនាយកដ្ឋានពន្ធដារធ្វើទស្សនកិច្ចតាមសហគ្រាសដើម្បីប្រមូលព័ត៌មាន នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០០៦អាចរកបាននៅ: http://bit.ly/2gPQNI0.
[28]សន្ទរកថាបើករបស់ឯ.ឧ.គង់ វិបុល អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៦ ក្នុងកម្មវិធីរបស់សភាពាណិជ្ជកម្មសហភាពអឺរ៉ុប អាចរកបាននៅ:http://bit.ly/2hnxp64.
[29]ក្រុមហ៊ុនSciaroni& Associates, សេចក្តីជូនដំណឹង លេខ:០៣៩ ស្តីពីអគ្គនាយកដ្ឋានពន្ធដារធ្វើទស្សនកិច្ចតាមសហគ្រាសដើម្បីប្រមូលព័ត៌មាន នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០០៦អាចរកបាននៅ: http://bit.ly/2gPQNI0.
[30]Kali Kotoski, “Income-tax threshold to rise,”កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៦ អាចរកបាននៅ:http://bit.ly/2gqJ6GT.

# ៦. បរិយាកាសពន្ធដារដោយផ្អែកលើទស្សនៈប្រឆាំងនឹងអំពើពុករលួយ

## ៦.១ ទស្សនៈរបស់ក្រុមហ៊ុនដែលបានបង់ពន្ធ

ប្រទេសកម្ពុជាស្ថិតនៅលេខរៀងទី១៣១ និង១៨០ ក្នុងចំណោម១៩០ប្រទេស តាមការស្ទង់មតិអំពីភាពងាយស្រួលក្នុងការធ្វើអាជីវកម្ម និងការចាប់ផ្តើមអាជីវកម្ម ដូចមានបង្ហាញក្នុងរូបទី៣ និងរូបទី៤។ ចំណាត់ថ្នាក់នៃភាពងាយស្រួលក្នុងការធ្វើអាជីវកម្ម គឺផ្តោតលើវដ្តនៃការធ្វើអាជីវកម្ម ដូចជាការចាប់ផ្តើមអាជីវកម្ម ការបញ្ជូន និងការអនុម័តលើការសាងសង់ ការតម្លើងអគ្គីសនី ការចុះបញ្ជីអចលនទ្រព្យ ការការពារវិនិយោគទុនតូចៗ ការបង់ពន្ធ ការជួញដូរឆ្លងកាត់ព្រំដែន ការអនុវត្តកិច្ចសន្យា ការដោះស្រាយបញ្ហាក្ស័យធន និងបទប្បញ្ញត្តិទីផ្សារការងារជាដើម។[31]

[31]ក្រុមធនាគារពិភពលោក ការធ្វើអាជីវកម្មឆ្នាំ២០១៧ World Bank Group Flagship Report 14th Ed., អាចរកបាននៅ: http://bit.ly/2eCMkup.

*រូបភាពទី៣ ការដាក់ចំណាត់ថ្នាក់លើភាពងាយស្រួលក្នុងការធ្វើអាជីវកម្មរបស់អាស៊ីខាងកើត និងប៉ាស៊ីហ្វិក*




*រូបភាពទី៤ ការដាក់ចំណាត់ថ្នាក់លើភាពងាយស្រួលក្នុងការចាប់ផ្តើមធ្វើអាជីវកម្មរបស់ អាស៊ីខាងកើត និងប៉ាស៊ីហ្វិក*



ទោះបីយ៉ាងណាក៏ដោយ គ្រប់អ្នកដែលត្រូវបានសម្ភាស បានធ្វើការកត់សម្គាល់ចំពោះការកែប្រែដ៏ច្រើនក្នុងដំណើរការនៃការចាប់ផ្ដើមធ្វើអាជីវកម្មនៅកម្ពុជា ជាពិសេសការចុះបញ្ជីពន្ធដារបើប្រៀបធៀបនឹងឆ្នាំកន្លងទៅ។ ការចុះបញ្ជី និងដំណើរការផ្ដល់អាជ្ញាប័ណ្ណជាក់ស្ដែង គឺមានលក្ខណៈច្បាស់លាស់ និងអាចបញ្ជាក់ប្រកបដោយប្រសិទ្ធភាព បើប្រៀបធៀបទៅនឹងទសវត្សកន្លងទៅ។ រាល់អាជីវកម្ម និងការវិនិយោគលើគ្រប់វិស័យត្រូវបានបើកចំហ និងមិនមានការហាមឃាត់លើវិស័យណាមួយនោះទេ ។ នៅក្នុងការចុះបញ្ជីអាជីវកម្មថ្មីមួយម្ចាស់អាជីវកម្មត្រូវស្នើសុំទៅ ៥ ក្រសួង/ស្ថាប័នផ្សេងៗគ្នា យ៉ាងហោចណាស់ មានដូចជា (i) ក្រសួងពាណិជ្ជកម្ម (ii) អគ្គនាយកដ្ឋានពន្ធដារ (iii) ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ (vi) ធនាគារ (v) មូលនិធិជាតិរបបសន្តិសុខសង្គម (បសស) ចំពោះសហគ្រាសទាំងឡាយណាដែលមាន និយោជិតចាប់ពី៨នាក់ ឬច្រើនជាងនេះត្រូវតែចុះបញ្ជីជាមួយ បសស។[32]

សម្រាប់អគ្គនាយកដ្ឋានពន្ធដារ ក្រុមហ៊ុនទាំងអស់ត្រូវអនុវត្តប្រព័ន្ធពន្ធដារដូចគ្នា គឺប្រព័ន្ធរបបស្វ័យប្រកាស ដែលចែកជាបីប្រភេទ៖ អ្នកជាប់ពន្ធតូច អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំ។ ការចុះបញ្ជីមានភាពងាយស្រួល និងអាចរកបាននៅលើគេហទំព័រអគ្គនាយកដ្ឋានពន្ធដារ។ រាល់ព័ត៌មានដែលបានចុះបញ្ជី នឹងត្រូវបានប្រមូលផ្ដុំទុកនៅមជ្ឈមណ្ឌលទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ។

តាំងពីដើមឆ្នាំ២០១៦មក គ្រប់អ្នកដែលត្រូវបានសម្ភាសបានធ្វើការកត់សម្គាល់ចំពោះការកែប្រែជាច្រើនក្នុងប្រព័ន្ធពន្ធដារ ដូចជា កំណែទម្រង់ស៊ីជម្រៅដែលធ្វើដោយអគ្គនាយកដ្ឋានពន្ធដារ។ ជាទូទៅ កំណែទម្រង់នេះត្រូវបានគេមើលឃើញថាជាជំហានដ៏ធំមួយឆ្ពោះទៅមុខក្នុងការប្រយុទ្ធប្រឆាំង អំពើពុករលួយក្នុងប្រព័ន្ធពន្ធដារនៅប្រទេសកម្ពុជា។ ក្រុមហ៊ុនស្ទើរទាំងអស់ទទួលស្គាល់ថា ការកែទម្រង់នាពេលថ្មីៗនេះបានកាត់បន្ថយការប្រព្រឹត្ត នូវអំពើពុករលួយបានច្រើន ដែលជាធម្មតាតែងកើតមានក្នុងដំណើរការនៃ (i) ការចុះបញ្ជីពន្ធដារ (ii) ការប្រមូលឯកសារពន្ធត្រឡប់មកវិញប្រចាំខែ (iii) ការធ្វើប័ណ្ណប៉ាតង់ថ្មី (iv) ការប្រមូលឯកសារពន្ធត្រឡប់មកវិញប្រចាំឆ្នាំ។ ជាពិសេសការកែប្រែដ៏សំខាន់បំផុតក្នុងប្រព័ន្ធពន្ធដារនោះ គឺការលុបចោលនូវពន្ធរបបម៉ៅការ គឺផ្ដល់អត្ថប្រយោជន៍ ជាច្រើនសម្រាប់អាជីវកម្មខ្នាតតូច ដែលមានផលរបរប្រចាំឆ្នាំតិចជាង២៥០លានរៀល (៦២ ៥០០ ដុល្លារ)។

យោងតាមលទ្ធផលនៃការស្ទង់មតិ អ្នកដែលត្រូវបានសម្ភាសខ្លះគិតថា ការគោរពកាតព្វកិច្ចបង់ពន្ធធ្វើឲ្យពួកគេចាញ់ប្រៀបទៅវិញបើធៀបនឹងអ្នកដែលមិនបានអនុវត្តតាមច្បាប់ពន្ធដារ ព្រោះការគោរពកាតព្វកិច្ចបង់ពន្ធប៉ះពាល់ដល់ការប្រកួតប្រជែង និងបង្កើតឲ្យមានបន្ទុកហិរញ្ញវត្ថុបន្ថែមលើអាជីវកម្មរួមមាន (i) ពន្ធកាត់ទុក (ii)

[32]រាល់អាជីវកម្មទាំងអស់តម្រូវឲ្យចុះបញ្ជីជាមួយនឹង៥ស្ថាប័នយ៉ាងតិច ទោះបីជាយ៉ាងណាក្រុមហ៊ុនមិនទាំងអស់ទេដែលបានបំពេញតាមតម្រូវការនេះ សូមមើលត្រង់នេះដើម្បីព័ត៌មានបន្ថែមដែលប្រមូលធ្វើគម្រោងនៃការធ្វើអាជីវកម្មដែលធ្វើដោយធនាគារពិភព http://bit.ly/2heABmC.

អាករលើតម្លៃបន្ថែម១០% (iii) ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ និង (iv) អំពើពុករលួយក្នុងប្រព័ន្ធពន្ធដារ។ កាតព្វកិច្ចទាំងនេះ បានសង្ខេបក្នុងរូបទី៥ខាងក្រោម៖

*រូបភាពទី៥ កត្តាដែលធ្វើឲ្យអ្នកបង់ពន្ធមិនពេញចិត្ត*




## (i) ពន្ធកាត់ទុក

យោងតាមច្បាប់ស្តីពីសារពើពន្ធ ក្រុមហ៊ុនដែលបានបង់ពន្ធលើការចំណាយពាក់ព័ន្ធទៅនឹងការជួលសេវាកម្មរបស់បុគ្គល ឬក្រុមហ៊ុនណាមួយដែលមិនអាចផ្តល់ឲ្យនូវវិក្កយបត្រដែលមានអាករលើតម្លៃបន្ថែម តម្រូវឲ្យធ្វើការកាត់ទុកនូវចំនួនសមាមាត្រនៃប្រាក់ដែលត្រូវបង់នោះពីអ្នកផ្តល់សេវាកម្ម និងត្រូវបង់ចំនួនសមាមាត្រជាពន្ធកាត់ទុកដែលកំណត់ ១៥%[33]ជាទូទៅ។ ជាផលវិបាក ការបង់នេះបានធ្វើឲ្យក្រុមហ៊ុនដែលបានបង់ពន្ធ មិនទទួលបានផលប្រយោជន៍នោះទេ បើប្រៀបធៀបនឹងក្រុមហ៊ុនដែលមិនបានបង់ពន្ធ ពីព្រោះក្រុមហ៊ុនដែលមិនបានបង់ពន្ធនឹងមិនត្រូវបង់ពន្ធកាត់ទុកនេះទេ។ អ្នកឆ្លើយតបការស្ទង់មតិស្ទើរតែទាំងអស់ បានផ្តល់អនុសាសន៍ឲ្យលុបចោលនូវពន្ធកាត់ទុកនេះ។

[33]ច្បាប់ស្តីពីសារពើពន្ធ ខែមករា ឆ្នាំ២០០៤ ត្រង់មាត្រា២៥ អាចរកបាននៅ:http://bit.ly/2hDdChV.

### (ii) អាករលើតម្លៃបន្ថែម១០%

គ្រប់ផលិតផល និងសេវាកម្មដែលលក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់អាករលើតម្លៃបន្ថែមក្នុងអត្រា១០%។ អាករលើតម្លៃបន្ថែមនេះពិតជាកាតព្វកិច្ចដែលអ្នកប្រើប្រាស់ចុងក្រោយត្រូវបង់ ប៉ុន្តែជាក់ស្តែងត្រូវបានគេប្រមូលពីក្រុមហ៊ុនដែលផ្គត់ផ្គង់ផលិតផល និងសេវាកម្មទៅវិញទេ។ អត្រាអាករលើតម្លៃបន្ថែម១០% បានក្លាយជាបន្ទុកផ្នែកហិរញ្ញវត្ថុលើតម្លៃលក់ សម្រាប់ក្រុមហ៊ុនដែលបានអនុវត្តការបង់ពន្ធត្រឹមត្រូវ ជាផលវិបាក វាធ្វើឲ្យក្រុមហ៊ុនដែលបានបង់ពន្ធត្រឹមត្រូវពិបាកក្នុងការប្រកួតលើតម្លៃផលិតផល ឬសេវាកម្មជាមួយនឹងក្រុមហ៊ុនដែលមិនបានបង់ពន្ធត្រឹមត្រូវ ។

### (iii) ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ

បន្ថែមពីលើនេះ ក្រុមហ៊ុនរួមទាំងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលជាប់ពន្ធលើប្រាក់ចំណេញតាមអត្រា៩ភាគរយមានកាតព្វកិច្ចបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញប្រចាំខែ តាមអត្រា១ភាគរយនៃផលរបរប្រចាំខែ គិតរួមទាំងពន្ធអាករគ្រប់ប្រភេទដែលសម្រេចបានក្នុងខែមុន លើកលែងតែអាករលើតម្លៃបន្ថែម។ ការណ៍នេះ ក្លាយជាបញ្ហាសម្រាប់អ្នកជាប់ពន្ធដែលកំពុងមានបញ្ហាចរន្តសាច់ប្រាក់ ហើយពួកគេបានស្នើសុំឲ្យធ្វើការកែប្រែដោយប្រកាសពន្ធជាប្រចាំខែ ជាជាងការប្រកាសប្រចាំឆ្នាំ។

### (iv) អំពើពុករលួយក្នុងប្រព័ន្ធពន្ធដារ

អ្នកឆ្លើយតបការស្ទង់មតិមួយចំនួនទទួលស្គាល់ថា នៅមានអំពើពុករលួយក្នុងប្រព័ន្ធពន្ធដារ ប៉ុន្តែក៏ពិបាកកំណត់ និងសឹងតែមិនអាចរកឃើញបាន ពីព្រោះថាការសុំគ្រលំគ្នារវាងអ្នកជាប់ពន្ធ និងមន្ត្រីពន្ធដារកើតមានជាសម្ងាត់។ បន្ថែមពីលើនេះ មានកត្តាដ៏ទៃទៀតដែលជម្រុញឲ្យមានអំពើពុករលួយរួមទាំងភាពស្មុគស្មាញនៃច្បាប់សារពើពន្ធ តួនាទីដ៏មានបុព្វសិទ្ធរបស់មន្ត្រីពន្ធដារ និងទម្លាប់ក្នុងការចំណាយក្រៅផ្លូវការ និងបរិយាកាសទូទៅនៃវិស័យសាធារណៈ។ កត្តាទាំងនេះបានចូលរួមចំណែកក្នុងការបង្កើតវប្បធម៌ពុករលួយដែលកំពុងតែមានក្នុងប្រព័ន្ធពន្ធដារ។

## ៦.២ ទស្សនៈរបស់ក្រុមហ៊ុនដែលមិនបានបង់ពន្ធ

ការបង់ពន្ធ គឺជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋគ្រប់រូបក្នុងប្រទេស ប៉ុន្តែប្រជាពលរដ្ឋមិនទាំងអស់នោះទេដែលមានឆន្ទៈបំពេញកាតព្វកិច្ចនេះ។ តាមទស្សនៈនេះ គំនិតទាក់ទិននឹងពន្ធដារគឺជាក្តីបារម្ភសម្រាប់ ប្រជាពលរដ្ឋ និងអាជីវកម្មជាច្រើននៅកម្ពុជាដែលជាប់កាតព្វកិច្ចបង់ពន្ធផ្សេងៗ ការប្រាស្រ័យទាក់ទងជាមួយមន្ត្រីពន្ធដារ នឹងបង្កើតឲ្យមានបញ្ហាជាច្រើនទៀតដែលមិនទាក់ទងនឹងពន្ធដារ។ ក្រៅពីកាតព្វកិច្ចបង់ពន្ធ ក៏មានឧបសគ្គដែលនាំឲ្យ អាជីវកម្មជាច្រើនមិនចុះបញ្ជីពន្ធដារជាមួយនឹងរដ្ឋបាលសារពើពន្ធផងដែរ ដូចជាការខ្វះការយល់ដឹង

ពីប្រព័ន្ធពន្ធដារ និងបទប្បញ្ញត្តិនានា ការយល់ឃើញខ្ពស់ចំពោះអំពើពុករលួយ លទ្ធភាពប្រកួតប្រជែងទាប ភាពស្មុគស្មាញនៃច្បាប់ពន្ធដារ ការលំបាករបស់បុគ្គល/សម្ភាធការងារ និងកង្វះតម្លាភាពក្នុងការផ្តល់សេវា និងទំនិញពីស្ថាប័នសាធារណៈ។ កត្តាទាំងអស់នេះ ត្រូវបានសង្ខេបដូចក្នុងរូបទី៦ខាងក្រោម៖

*រូបភាពទី៦ កត្តាដែលរារាំងក្រុមហ៊ុនពីរដ្ឋបាលសារពើពន្ធ*




### ៦.២.១ ការខ្វះការយល់ដឹងពីប្រព័ន្ធពន្ធដារ និងបទប្បញ្ញត្តិនានា

អ្នកឆ្លើយតបនឹងការស្ទង់មតិទាំងអស់ទទួលស្គាល់ថាពន្ធដារ គឺជាប្រភពចំណូលចំបងរបស់រដ្ឋាភិបាល ហើយមូលនិធិនេះត្រូវប្រើប្រាស់ដើម្បីបំពេញតម្រូវការជាមូលដ្ឋានរបស់ប្រជាពលរដ្ឋទូទៅដូចជាសុវត្ថិភាព ការការពារសន្តិភាព និងសណ្តាប់ធ្នាប់សង្គម។ ទោះបីយ៉ាងណាក៏ដោយ ក្រុមហ៊ុនទាំងនោះមិនបានយល់ដឹងច្បាស់លាស់ អំពីដំណើរការនៃប្រព័ន្ធពន្ធដារ និងបទប្បញ្ញត្តិពន្ធដារនៅកម្ពុជា។ ក្រុមហ៊ុនទាំងនោះបានចាត់ទុកពន្ធ គឺជាបន្ទុកហិរញ្ញវត្ថុទៅវិញ។ ជាលទ្ធផល ក្រុមហ៊ុនភាគច្រើនមិនចុះបញ្ជីអាជីវកម្មជាមួយនឹងរដ្ឋបាលសារពើពន្ធនោះទេ។

### ៦.២.២ ការយល់ឃើញខ្ពស់ចំពោះអំពើពុករលួយ

ដូចដែលបានរៀបរាប់ខាងដើម ប្រទេសកម្ពុជាត្រូវបានគេយល់ឃើញថា ជាប្រទេសដែលមានអំពើពុករលួយកំរិតខ្ពស់ក្នុងពិភពលោក ដូច្នេះសមាជិកមួយចំនួននៃសហគមន៍ពាណិជ្ជកម្មមិនប្រាកដថា តើប្រាក់បង់ពន្ធរបស់ពួកគេនឹងពិតជាត្រូវបានប្រើប្រាស់ ដើម្បីធ្វើហិរញ្ញប្បទានដល់ផលិតផល និងសេវាសាធារណៈ ឬយ៉ាងណា ការណ៍នេះនាំឲ្យពួកគេព្យាយាមគេចវេះពីកាតព្វកិច្ចបង់ពន្ធ។ ក្រុមហ៊ុនអាចពិចារណាមិនចុះបញ្ជី ប្រសិនបើតម្លៃនៃការសូកប៉ាន់មន្ត្រីពន្ធដារទាបជាងផលប្រយោជន៍ដែលក្រុមហ៊ុនទទួលបាន បើក្រុមហ៊ុននោះគោរពតាមច្បាប់ពន្ធដារ ។

### ៦.២.៣ លទ្ធភាពប្រកួតប្រជែងទាប

យោងតាមការឆ្លើយតបពីការស្ទង់មតិ ជាញឹកញាប់ប្រព័ន្ធពន្ធដារនាំឲ្យអាជីវកម្មរបស់ពួកគេចាញ់ប្រៀបក្នុងការប្រកួតប្រជែង ប្រសិនបើពួកគេធ្វើការចុះបញ្ជីអាជីវកម្មនៅអគ្គនាយកដ្ឋានពន្ធដារ ពីព្រោះពួកគេត្រូវបង់អាករលើតម្លៃបន្ថែម(១០%) ពន្ធកាត់ទុកប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ពន្ធលើប្រាក់ចំណេញ និងការចំណាយថ្លៃរដ្ឋបាលដទៃផ្សេងទៀតនៅក្នុងអំឡុងពេល និងក្រោយដំណើរការចុះបញ្ជីរួច។

### ៦.២.៤ ភាពស្មុគស្មាញនៃច្បាប់ពន្ធដារ

ភាពស្មុគស្មាញនៃច្បាប់ពន្ធដារ និងបទប្បញ្ញត្តិដែលមានជាមួយនឹងច្បាប់នោះ ក៏នាំដល់ការពន្យារ ឬមិនអើពើក្នុងការបំពេញការចុះបញ្ជីពន្ធដាររបស់ពួកគេ។ ក្នុងការពិភាក្សារឿងច្បាប់ពន្ធដារ និងបទប្បញ្ញត្តិនានា សមាជិកនៃសហគមន៍ពាណិជ្ជកម្មមានការព្រួយបារម្ភចំពោះ ការទំនាក់ទំនងជាមួយមន្ត្រីពន្ធដារ និងបញ្ហាចំណេះដឹងពីបទប្បញ្ញត្តិពន្ធដារនានា។

### ៦.២.៥ ការលំបាកបុគ្គល/សម្ពាធភាតព្វកិច្ច

ការលំបាកផ្ទាល់ខ្លួន ការខ្វះឆន្ទៈ និងសម្ពាធការងារ ទំនងជារុញច្រានអ្នកជាប់ពន្ធមិនឲ្យចុះបញ្ជីពន្ធដារជាមួយនឹងអគ្គនាយកដ្ឋានពន្ធដារ ពីព្រោះតែការចុះបញ្ជីពន្ធដារ គឺជាការជាប់បន្ទុក។ ជាពិសេស អ្នកឆ្លើយតបការស្ទង់មតិបារម្ភពីការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ពន្ធលើប្រាក់បៀវត្សអាករស្នាក់នៅ និង២០%នៃចំនួនអាករលើតម្លៃបន្ថែម។[34] ជាងនេះទៅទៀត អាជីវកម្មដែលបានចុះបញ្ជីត្រូវប្រកាសពន្ធ លើប្រាក់ចំណេញប្រចាំឆ្នាំ និងបង់ពន្ធប៉ាតង់រៀងរាល់ឆ្នាំ។ កាតព្វកិច្ចទាំងអស់នេះហើយដែលជាមូលហេតុនាំឲ្យមានការខ្វះការលើកទឹកចិត្តសម្រាប់ម្ចាស់អាជីវកម្ម ក្នុងការចុះបញ្ជីពន្ធដារជាមួយនឹងរដ្ឋបាលសារពើពន្ធ។

[34]ជាទូទៅ ការផ្គត់ផ្គង់ទំនិញ ឬសេវាកម្មទៅឲ្យទីផ្សារក្នុងស្រុកត្រូវជាប់ពន្ធVAT១០% ប៉ុន្តែមានការលើកលែងចំពោះអ្នកជាប់ពន្ធតូច។ អ្នកជាប់ពន្ធតូចត្រូវបង់តែ២០%នៃចំនួនVATសរុបប៉ុណ្ណោះ។

### ៦.២.៦ កង្វះតម្លាភាពក្នុងការផ្តល់សេវាសាធារណៈ និងធនធាន

កង្វះតម្លាភាពក្នុងការប្រើប្រាស់មូលនិធិសាធារណៈបាននាំឲ្យមានការមិនទុកចិត្តចំពោះប្រព័ន្ធពន្ធដារ និងការចំណាយរបស់រដ្ឋាភិបាល។ មូលនិធិដែលត្រូវយកទៅកសាងផ្លូវ ស្ពាន សាលារៀន និងអគារមន្ទីរពេទ្យ ត្រូវបានគេយល់ឃើញថា មានការគ្រប់គ្រងអន់ខ្សោយ។ ជាលទ្ធផលអាជីវកម្មខ្នាតតូចជាច្រើន មិនចង់ចុះបញ្ជីអាជីវកម្មរបស់ពួកគេជាមួយនឹងអគ្គនាយកដ្ឋានពន្ធដារ ឬស្ថាប័នមានសមត្ថកិច្ចណាមួយឡើយ។

# ៧. មូលហេតុ និងផលប៉ះពាល់នៃអំពើពុករលួយលើប្រព័ន្ធពន្ធដារ

## ៧.១ មូលហេតុនៃអំពើពុករលួយ

អំពើពុករលួយបានបង្កជាឧបសគ្គដល់ដំណើរការប្រមូលពន្ធនៅកម្ពុជាជាច្រើនទសវត្សមកហើយ។ យោងតាមការស្ទង់មតិមួយរបស់ធនាគារពិភពលោកឆ្នាំ២០១៦ បានឲ្យដឹងថា អាជីវកម្មប្រមាណជា ៥៨,៧ ភាគរយរំពឹងថា នឹងផ្តល់សំណូក ឬកម្រៃក្រៅផ្លូវការក្នុងការជួបជាមួយនឹងមន្ត្រីពន្ធដារ។[35] ជាងនេះទៀត ផ្អែកលើសន្ទស្សន៍នៃការយល់ឃើញអំពីអំពើពុករលួយឆ្នាំ២០១៥ បានបង្ហាញថាកម្ពុជាទទួលបានពិន្ទុ២១ នៃ១០០ពិន្ទុ។ នេះបង្ហាញថាទោះបីជាមានការកែលម្អ និងកំណែទម្រង់ផ្សេងៗនៅក្នុងវិស័យមួយចំនួនក៏ដោយ ក៏ការយល់ឃើញរបស់វិស័យឯកជនចំពោះសេវាសាធារណៈ គឺនៅតែមានកម្រិតទាបនៅឡើយ។ [36]

ក្នុងចំណោមអាជីវកម្មចំនួន១២ដែលបានចូលរួមក្នុងការស្ទង់មតិ ក៏បានបង្ហាញថាមានកត្តាផ្សេងៗទៀតដែលជម្រុញឲ្យមានការប្រព្រឹត្តអំពើពុករលួយក្នុងប្រព័ន្ធពន្ធដារ។ កត្តាទាំងនោះរួមមាន៖

- ភាពស្មុគស្មាញនៃច្បាប់ពន្ធដារ
- អំណាចផ្តាច់មុខរបស់មន្ត្រីពន្ធដារ
- ផលប្រយោជន៍ទៅវិញទៅមក
- ប្រព័ន្ធឧបត្ថម្ភក្រៅផ្លូវការដើម្បីទទួលបានផលប្រយោជន៍អ្វីមួយ
- ទម្លាប់នៃការបង់ប្រាក់ដោយបុគ្គលសម្រាប់ការសម្របសម្រួលការងារ ទៅឲ្យមន្ត្រីសាធារណៈក្នុងវិស័យឯកជន និង
- បរិយាកាសទូទៅនៃរដ្ឋបាលសាធារណៈ

[35] ធនាគារពិភពលោក ការស្ទង់មតិអំពីសហគ្រាស ព័ត៌មានសង្ខេបអំពីប្រទេសកម្ពុជា ឆ្នាំ២០១៦អាចរកបាននៅ:http://bit.ly/2hDrzfY.
[36] អង្គការតម្លាភាពអន្តរជាតិ ឧបករណ៍វាស់វែងអំពើពុករលួយ ឆ្នាំ២០១៥អាចរកបាននៅ:http://bit.ly/2gCI7qN.

### ៧.១.១ ភាពស្មុគស្មាញនៃច្បាប់ពន្ធដារ

ការស្ទង់មតិបានឲ្យដឹងថា ភាពស្មុគស្មាញនៃច្បាប់ពន្ធដារ និងបទប្បញ្ញត្តិសារពើពន្ធ បង្កើននូវហានិភ័យកាន់តែខ្ពស់ក្នុងការប្រព្រឹត្តអំពើពុករលួយក្នុងប្រព័ន្ធពន្ធដារ ជាពិសេសក្នុងដំណើរការធ្វើសវនកម្ម។ ការខ្វះខាតនូវព័ត៌មាន បានធ្វើឲ្យអ្នកជាប់ពន្ធមិនបានដឹងពីកាតព្វកិច្ចរបស់ខ្លួន និងធ្វើឲ្យពួកគេប្រឈមនឹងការកេងយកផលប្រយោជន៍ពីអ្នកដទៃកាន់តែខ្លាំង។ ទន្ទឹមនឹងនេះ ការគេចពន្ធ និងការមិនចង់បង់ពន្ធរឹតតែទំនងជាកើតមាននៅក្នុងបរិយាកាសដែលមានអំពើពុករលួយខ្លាំង។ ការណ៍នេះ លើកទឹកចិត្តអ្នកជាប់ពន្ធភាគច្រើនមិនឲ្យទាក់ទងទៅអគ្គនាយកដ្ឋានពន្ធដារ ឬមន្ត្រីពន្ធដារដោយផ្ទាល់ដែរ ប៉ុន្តែត្រូវធ្វើការជាមួយអន្តរការីផ្នែកពន្ធដារជាពិសេសអ្នកពិគ្រោះយោបល់ខាងពន្ធដារជំនួសវិញ។

ក្រៅពីភាពស្មុគស្មាញនៃច្បាប់ពន្ធដារ ការមិនអើពើ និងភាពខ្វះឆន្ទៈក្នុងការសិក្សាស្វែងយល់ ក៏ជាកត្តារួមចំណែកដល់ការប្រព្រឹត្តអំពើពុករលួយក្នុងវិស័យឯកជនផងដែរ។ អ្នកជាប់ពន្ធដែលព្រងើយកន្តើយ ប្រឈមខ្លាំងនឹងការសូកប៉ាន់មន្ត្រីពន្ធដារ និងឈ្មួញកណ្តាលដែលនាំឲ្យពួកគេភាន់ច្រឡំតាមរយៈការពន្យល់ពីនីតិវិធីសារពើពន្ធមិនបានត្រឹមត្រូវ។

### ៧.១.២ អំណាចផ្តាច់មុខរបស់មន្ត្រីពន្ធដារ

ក្រៅពីអ្វីដែលគេហៅថាអ្នកប្រមូលពន្ធ មន្ត្រីពន្ធដារក៏ត្រូវបានគេយល់ថាជាអ្នករុករកនូវបញ្ហាផ្សេងៗពាក់ព័ន្ធ នឹងការបង់ពន្ធរបស់អាជីវកម្មផងដែរ ដោយសារតែតួនាទីឯកសិទ្ធរបស់គេក្នុងប្រព័ន្ធពន្ធដារ។ បរិយាកាសពោរពេញដោយសម្ពាធ និងមានភាពផ្តាច់មុខផ្តល់ឲ្យមន្ត្រីពន្ធដារនូវឱកាសទាក់ទាញឲ្យអ្នកជាប់ពន្ធប្រព្រឹត្តនូវអំពើពុករលួយ ដោយចំណាយកម្រៃមិនផ្លូវការ។ អ្នកដែលមានសិទ្ធសម្រេចកាន់តែធំ ឱកាសសម្រាប់មន្ត្រីពន្ធដារក្នុងការរំលោភអំណាចដែលផ្តល់ឲ្យដើម្បីទារនូវកម្រៃក្រៅផ្លូវការក៏កាន់តែច្រើន ដើម្បីផ្តល់នូវការអនុគ្រោះ ចំពោះការបកស្រាយបទប្បញ្ញត្តិពន្ធដារដល់អាជីវកម្ម។

### ៧.១.៣ ផលប្រយោជន៍ទៅវិញទៅមក

គោលដៅតែមួយក្នុងការបង្កើនប្រាក់ចំណេញជាអតិបរមា និងកាត់បន្ថយថ្លៃចំណាយឲ្យកាន់តែតិច គឺជារឿងធម្មតាសម្រាប់គ្រប់អាជីវកម្មទាំងអស់ ទោះបីជាមានក្រុមហ៊ុនមួយចំនួនព្យាយាមសូកប៉ាន់មន្ត្រី ដើម្បីទទួលបាននូវការបង់ពន្ធក្នុងតម្លៃទាបជាងតម្លៃធម្មតា។ ជាលទ្ធផល ក្រុមហ៊ុនទាំងនោះ និងមន្ត្រីពន្ធដារជាអ្នកទទួលបានផលប្រយោជន៍ ហើយក្រុមហ៊ុនដែលអនុវត្តការបង់ពន្ធត្រឹមត្រូវ គឺមិនទទួលបានអត្ថប្រយោជន៍ទេ។

### ៧.១.៤ ប្រព័ន្ធបរិបាលកិច្ច

បរិបាលកិច្ចក្នុងប្រព័ន្ធពន្ធដារបង្កើនឱកាសក្នុងការគេចពន្ធ និងបង្កើតឲ្យមានអំពើពុករលួយ។ ប្រព័ន្ធបរិបាលកិច្ចដែលកើតមាននៅកម្ពុជា គឺជាក្តីបារម្ភដ៏ធំសម្រាប់បុគ្គល ទាំងឡាយណាដែលគោរពតាមបទប្បញ្ញត្តិពន្ធដារ ជាពិសេសសម្រាប់ក្រុមហ៊ុនបរទេស។ ក្រុមហ៊ុនបរទេសជួនកាលយល់ថា ខ្លួនឯងស្ថិតក្នុងស្ថានភាពមិនទទួលបានអត្ថប្រយោជន៍ទេ បើប្រៀបធៀបនឹងក្រុមហ៊ុនដែលអាចប្រតិបត្តិអាជីវកម្មរបស់ខ្លួនបានល្អក្នុងវប្បធម៌បរិបាលកិច្ច។ ប្រព័ន្ធបរិបាលកិច្ចហាក់ដូចជាកើតមានច្រើនក្នុងអាជីវកម្មឈើ ឧស្សាហកម្មផលិត និងការសាងសង់អគារសាធារណៈ។

### ៧.១.៥ ទម្លាប់នៃការបង់ប្រាក់សម្រាប់ការសម្របសម្រួល

ក្នុងការស្ទង់មតិ អ្នកឆ្លើយតបខ្លះបានបង្ហាញថា មានបុគ្គលមួយចំនួននៅតែរក្សានូវទម្លាប់បង់ប្រាក់សម្រាប់ការសម្របសម្រួល ទោះបីជាពួកគេមិនរងគំនាបក៏ដោយ។ ទម្លាប់នេះជាធម្មតាកើតមាននៅពេលប្រកាសពន្ធប្រចាំខែ និងការប្រកាសពន្ធប្រចាំឆ្នាំ។

### ៧.១.៦ បរិយាកាសទូទៅនៃរដ្ឋបាលសាធារណៈ

អំពើពុករលួយក្នុងរដ្ឋបាលសាធារណៈត្រូវបានយល់ឃើញថា ជារឿងធម្មតា ហើយវាបន្តកើតមានជាលក្ខណៈប្រព័ន្ធនៅកម្ពុជា។ ទីបំផុត ការខ្វះគណនេយ្យភាព និងតម្លាភាពរបស់អ្នកផ្តល់សេវាសាធារណៈ នាំទៅដល់ការផ្តល់នូវផលិតផល និងសេវាសាធារណៈដែលមានគុណភាពអន់។

## ៧.២ ផលប៉ះពាល់នៃអំពើពុករលួយលើប្រព័ន្ធពន្ធដារ

អំពើពុករលួយ គឺជាកត្តាចំបងដែលកាត់បន្ថយចំណូលពន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា និងបង្ខំឲ្យរាជរដ្ឋាភិបាលកម្ពុជាស្វែងរកប្រភពហិរញ្ញវត្ថុដ៏ទៃផ្សេងទៀតសម្រាប់ការចំណាយរបស់ខ្លួន ដូចជាត្រូវខ្ចីកម្ចីហិរញ្ញវត្ថុពីប្រទេសផ្សេងទៀត រួមមានប្រទេសចិនជាដើម។ កង្វះមូលនិធិរបស់រដ្ឋាភិបាល អាចធ្វើឲ្យមានបញ្ហាស្ថេរភាពនយោបាយរបស់ប្រទេសដែលបង្កដោយភាពចលាចលក្នុងសង្គម។ ផលប៉ះពាល់នៃអំពើពុករលួយចំពោះប្រទេស អាចធ្វើឲ្យប្រជាពលរដ្ឋខ្លួនបាត់បង់នូវទំនុកចិត្តលើលទ្ធិប្រជាធិបតេយ្យ អ្នកដឹកនាំស្ថាប័ននានា ប្រជាពលរដ្ឋកម្ពុជា ពាណិជ្ជកម្ម និងការវិនិយោគ ប្រសិទ្ធភាពខាងរដ្ឋបាល អភិបាលកិច្ចល្អ និងសមភាពរបស់ប្រជាពលរដ្ឋ។

ជាញឹកញាប់ ការសហការជាសម្ងាត់រវាងអ្នកជាប់ពន្ធ និងមន្ត្រីពន្ធដារ បានធ្វើឲ្យអ្នកជាប់ពន្ធដែលស្មោះត្រង់ ងាយរងគ្រោះ និងលើកទឹកចិត្តពួកគេក្នុងការស្វះស្វែងរកនូវជម្រើសផ្សេងទៀតដើម្បីរស់រាន ដូចជាត្រូវគេចពន្ធ និងអនុវត្តអំពើពុករលួយផ្សេងៗ ជាចុងក្រោយបណ្តាលឲ្យមាននូវផលប៉ះពាល់ជាបន្តបន្ទាប់មិនចេះចប់។

ក្រៅពីផលប៉ះពាល់លើក្រុមហ៊ុនដែលបានចុះបញ្ជីពន្ធដារត្រឹមត្រូវ អំពើពុករលួយក៏បង្អាក់ដំណើរការអាជីវកម្មដែលមិនចុះបញ្ជីមួយចំនួនពីការអនុវត្តតាមបទប្បញ្ញត្តិពន្ធដារ ពីព្រោះភាគច្រើនពួកគេបារម្ភអំពីការបង់សំណូកជូនមន្ត្រីពន្ធដារ។

# ៨ សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ក្នុងកិច្ចខិតខំប្រឹងប្រែងបង្កើតបរិយាកាសធុរកិច្ចឲ្យកាន់តែមានការប្រកួតប្រជែងស្មើភាពគ្នា រាជរដ្ឋាភិបាលកម្ពុជាបានលុបចោលនូវរបបពន្ធម៉ៅការដើម្បីអនុគ្រោះ ឲ្យប្រព័ន្ធពន្ធដារមានភាពស៊ីសង្វាក់គ្នា និរន្តភាព និងតម្លាភាព។ ក្របខ័ណ្ឌកំណែទម្រង់ទទួលបានការស្ញើចសរសើរខ្លាំង និងស្វាគមន៍ពីសមាជិកនៃសហគមន៍អាជីវកម្មជាច្រើន។ អ្នកឆ្លើយតបការស្ទង់មតិស្ទើរតែទាំងអស់បានទទួលស្គាល់ថា រាជរដ្ឋាភិបាលបានលើកកម្ពស់បរិយាកាសធុរកិច្ច ឲ្យកាន់តែប្រសើរឡើងសម្រាប់អ្នកធ្វើធុរកិច្ចទាំងឡាយតាមរយៈការធ្វើឲ្យប្រសើរឡើងនូវ៖ (i) នីតិវិធីចុះបញ្ជីពន្ធដារ (ii) នីតិវិធីការប្រកាសពន្ធប្រចាំខែ (iii) នីតិវិធីការប្រកាសពន្ធប្រចាំឆ្នាំ (iv) នីតិវិធីបន្តពន្ធប៉ាតង់ និង (v) នីតិវិធីសវនកម្មពន្ធដារ និងការគ្រប់គ្រង។ ការលើកលែងអាករលើតម្លៃបន្ថែមរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់អាជីវកម្មខ្នាតតូច ត្រូវបានគេយល់ឃើញថា ជាមូលដ្ឋានគ្រឹះដើម្បីការរីកចម្រើនរបស់អាជីវកម្មខ្នាតតូច។ ក្រៅពីការធ្វើឲ្យប្រសើរឡើងទាំងនេះ កម្ពុជានៅមានកិច្ចការត្រូវធ្វើច្រើនបន្ថែមទៀតដើម្បីជម្រុញឲ្យបរិយាកាសកាន់តែមានភាពអនុគ្រោះ និងកាន់តែមានភាពប្រកួតប្រជែងដើម្បីការរីកចម្រើនរបស់បរិយាកាសអាជីវកម្មទូទៅ។ អង្គការតម្លាភាពកម្ពុជាសូមផ្តល់ជូននូវអនុសាសន៍ចំពោះ រាជរដ្ឋាភិបាលកម្ពុជាដូចខាងក្រោមៈ

## អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលកម្ពុជា

១. កម្មវិធីផ្តល់ជំនួយ និងការអប់រំអ្នកជាប់ពន្ធ៖ ច្បាប់ស្តីពីសារពើពន្ធគួរតែផ្សព្វផ្សាយឲ្យបានកាន់តែទូលំទូលាយ ជាពិសេសចំពោះអ្នកជាប់ពន្ធតូច និងក្រុមហ៊ុនដែលមិនបានអនុវត្តតាមច្បាប់ត្រឹមត្រូវ។ អគ្គនាយកដ្ឋានពន្ធដារ គួរតែបន្តធ្វើបច្ចុប្បន្នភាពផ្សព្វផ្សាយដល់សាធារណៈជនអំពីការងារកំណែទម្រង់របស់ខ្លួន និងចំណុចដែលមានការកែប្រែចំពោះច្បាប់។

២. ពង្រឹងភាពជាអ្នកដឹកនាំឲ្យកាន់តែខ្លាំង៖ សារៈសំខាន់សម្រាប់ថ្នាក់ដឹកនាំក្នុងវិស័យសាធារណៈគឺ ការដឹកនាំជាគំរូ និងសំដែងឲ្យឃើញនូវសីលធម៌ខ្ពស់ក្នុងការអនុវត្តការងារ និងការផ្តល់យុត្តិធម៌នៅក្នុងការដោះស្រាយបញ្ហាផ្សេងៗជាមួយនឹងមន្ត្រីបុគ្គលិក និងមនុស្សទូទៅ។

៣. លើកកម្ពស់តម្លាភាពនៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានពន្ធដារ៖ ចំពោះការសម្រេចបាននូវគោលដៅនៃការធ្វើកំណែទម្រង់របស់ខ្លួន និងការវិវត្តន៍រីកចម្រើនផ្សេងៗទៀតដែលក្រសួងបានធ្វើ។

៤. បង្កើតឲ្យមានប្រសិទ្ធភាពក្នុងការអនុវត្តការងាររបស់ការិយាល័យរដ្ឋបាលសារពើពន្ធ៖ ដោយមានធនធានមនុស្សគ្រប់គ្រាន់ មានគណនេយ្យភាព និងការទទួលខុសត្រូវ ដើម្បីឆ្លើយតបរាល់ចម្ងល់ទាំងឡាយទាក់ទងនឹងពន្ធដារ និងធ្វើការបកស្រាយច្បាប់ និងបទប្បញ្ញត្តិសារពើពន្ធប្រកបដោយប្រសិទ្ធភាព។

៥. បង្កើតប្រព័ន្ធលើកទឹកចិត្តដែលសមរម្យមួយដល់វិស័យឯកជន ដើម្បីលើកទឹកចិត្តក្រុមហ៊ុនផ្សេងទៀតឲ្យបង់ពន្ធ។

៦. លុបបំបាត់នូវពន្ធកាត់ទុក។

៧. រដ្ឋាភិបាលគួរតែទុកពេល(ពីរទៅបីឆ្នាំ) សម្រាប់អ្នកបង់ពន្ធតូចឲ្យរៀបចំខ្លួនក្នុងការអនុវត្តតាមការប្រែប្រួលនៅក្នុងនិតិវិធីពន្ធដារ។ នេះគឺជាដំណើរការពីរជំហានដែលតម្រូវឲ្យអ្នកបង់ពន្ធតូចចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារជាមុនសិន ហើយបន្ទាប់មកមិនតម្រូវឲ្យពួកគេបង់ពន្ធទេ អំឡុងរយៈពេលពីរទៅបីឆ្នាំដំបូង។

៨. លើកទឹកចិត្តក្រុមហ៊ុនឲ្យអនុវត្តនូវប្រព័ន្ធសុចរិតភាពសាជីវកម្ម និងលើកកម្ពស់ការយល់ដឹងពីអត្ថប្រយោជន៍នៃការគោរពច្បាប់ពន្ធ។

## អនុសាសន៍សម្រាប់វិស័យឯកជន

១. បង្កើនការសម្របសម្រួលដើម្បីពិភាក្សា និងលើកកម្ពស់ការយល់ដឹងអំពីការកែប្រែទាំងឡាយដែលមានក្នុងច្បាប់។

២. បង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការតស៊ូមតិដើម្បីធ្វើឲ្យច្បាប់ និងបទប្បញ្ញត្តិនានាប្រសើរឡើងដែលនឹងជួយធ្វើឲ្យប្រព័ន្ធពន្ធដារកាន់តែមានភាពច្បាស់លាស់ឡើង និងការលុបបំបាត់អំពើពុករលួយ។

៣. គួរទទួលយក និងអនុវត្តប្រព័ន្ធសុចរិតភាពធុរកិច្ច ហើយលើកទឹកចិត្តដល់ក្រុមហ៊ុនដទៃទៀតឲ្យអនុវត្តតាម ក្នុងនោះរួមមានការបង្កើតឲ្យមានគោលការណ៍ប្រឆាំងនឹងការស៊ីសំណូក និងការបង់ប្រាក់សម្រាប់ការសម្របសម្រួល ដើម្បីបង្កើតនូវវប្បធម៌នៃការធ្វើអាជីវកម្មដែលគោរពច្បាប់ពន្ធដារ និងគ្មានអំពើពុករលួយ។

## អនុសាសន៍សម្រាប់សង្គមស៊ីវិល

១. ជួយផ្សព្វផ្សាយច្បាប់ និងលើកកម្ពស់ឲ្យមានការយល់ដឹងអំពីការកែប្រែបទប្បញ្ញត្តិពន្ធ។

២. ធ្វើការជិតស្និទ្ធជាមួយវិស័យឯកជន ដើម្បីជម្រុញបរិយាកាសធុរកិច្ចមិនឲ្យមានអំពើពុករលួយ។

# ៩ ឯកសារយោង


កិច្ចសម្ភាសន៍របស់ទូរទស្សន៍បាយ័នជាមួយនឹង ឯ.ឧ គង់ វិបុល អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ( GDT )នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦

Bertelsmann Transformation Index, របាយការណ៍ប្រទេសកម្ពុជាឆ្នាំ២០១០ អាចរកបាននៅ:http://bit.ly/2gBxFjh.

ក្រុមហ៊ុន Bun & Associates, មគ្គុទ្ទេសន៍ណែនាំ អំពីប្រព័ន្ធពន្ធដារនៅកម្ពុជាឆ្នាំ២០១៤ អាចរកបាននៅ: http://bit.ly/2gByFnm.

ក្រុមហ៊ុន DFDL, កូនសៀវភៅ មគ្គុទ្ទេសន៍ពន្ធដារចំពោះការវិនិយោគនៅកម្ពុជាឆ្នាំ២០១៦ អាចទាញយកទុកបាននៅ: http://bit.ly/2hrJIyg.

សភាពាណិជ្ជកម្មសហភាពអឺរ៉ុប (EuroCham) សៀវភៅស ស្តីពីអនុសាសន៍លើគោលនយោបាយពាណិជ្ជកម្ម និង ការវិនិយោគ ខែមីនា ឆ្នាំ២០១៦ អាចរកបាននៅ:http://bit.ly/2hrCA56

Kali Kotoski, “Income-tax threshold to rise,” កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៦ អាចរកបាននៅ: http://bit.ly/2gqJ6GT.

ច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០១៦ ព្រះរាជក្រម លេខ នស/រក/១២១៥/០៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានពន្ធដារ ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ អាចរកបាននៅ: http://bit.ly/2hjODUp.

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រកាសស្តីពីការអនុវត្តអាករលើតម្លៃបន្ថែម (VAT) ដើម្បីគាំទ្រឧស្សាហកម្ម ឬអ្នកម៉ៅការដែលផ្គត់ផ្គង់ទំនិញ ឬសេវាកម្មសម្រាប់បម្រើឲ្យការនាំចេញនៃឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ ឧស្សាហកម្មផលិតស្បែកជើង ឧស្សាហកម្មផលិតកាបូបស្ពាយ និងកាបូបដៃ និងឧស្សាហកម្មផលិតមួក តាមប្រកាសលេខ៣១១ សហវ/ប្រក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ អាចរកបាននៅ:http://bit.ly/2hCtxwR.

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រកាសស្តីពីពន្ធលើប្រាក់បៀវត្ស លេខ១១៧៣ សហវ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣ អាចរកបាននៅ:http://bit.ly/2hCtmSn.

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានពន្ធដារប្រកាសស្តីពីពន្ធលើប្រាក់ចំណេញ លេខ១០៥៩ សហវ.ប្រក.ពដ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ អាចរកបាននៅ:http://bit.ly/2hjKNe0.

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ច្បាប់ស្តីពីសារពើពន្ធ ខែមករា ឆ្នាំ២០០៤ អាចរកបាននៅ:http://bit.ly/2hDdChV.

ក្រុមហ៊ុន Sciaroni & Associates, សេចក្តីជូនដំណឹង លេខ:០៣៩ ស្តីពីអគ្គនាយកដ្ឋានពន្ធដារធ្វើទស្សនកិច្ចតាមសហគ្រាសដើម្បីប្រមូលព័ត៌មាន នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០០៦ អាចរកបាននៅ:http://bit.ly/2gPQNI0.

ក្រុមហ៊ុន TRACE International, Inc. 2016 Trace Matrix, អាចរកបាននៅ:http://bit.ly/2htlVRw

អង្គការតម្លាភាពអន្តរជាតិ ឧបករណ៍វាស់វែងអំពើពុករលួយ ឆ្នាំ២០១៥ អាចរកបាននៅ:http://bit.ly/2gCI7qN.

អង្គការតម្លាភាពអន្តរជាតិ តើអំពើពុករលួយគឺជាអ្វី? អាចរកបាននៅ:http://bit.ly/2hk4wqT.

ព្រឹត្តិបត្រអំពីបច្ចុប្បន្នភាពពន្ធដារកម្ពុជារបស់ក្រុមហ៊ុន VDB/Loi, ការវិវត្តន៍ចុងក្រោយនៃពន្ធលើអត្ថប្រយោជន៍ផ្សេងៗ អាចរកបាននៅ:http://bit.ly/2gC4lsD.

ចំណាត់ថ្នាក់អំពើពុករលួយនៃការធ្វើសវនកម្មជាសាកលឆ្នាំ២០១៥ អាចរកបាននៅ:http://bit.ly/1Xow5gK

ក្រុមធនាគារពិភពលោក ការធ្វើអាជីវកម្មឆ្នាំ២០១៧ World Bank Group Flagship Report 14th Ed., អាចរកបាននៅ: http://bit.ly/2eCMkup.

ក្រុមធនាគារពិភពលោក ចំណាត់ថ្នាក់សេដ្ឋកិច្ច ខែមិថុនា ឆ្នាំ២០១៦ អាចរកបាននៅ:http://bit.ly/K11iGM.

ធនាគារពិភពលោក ការស្ទង់មតិអំពីសហគ្រាស ព័ត៌មានសង្ខេបអំពីប្រទេសកម្ពុជា ឆ្នាំ២០១៦ អាចរកបាននៅ: http://bit.ly/2hDrzfY.

ក្រុមធនាគារពិភពលោក ជួយប្រទេសនានាប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយៈ តួនាទីរបស់ធនាគារពិភពលោក អាចរកបាននៅ:http://bit.ly/1G8kxVo.

សុន្ទរកថាបើករបស់ឯ.ឧ.គង់ វិបុល អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៦ ក្នុងកម្មវិធីរបស់សភាពាណិជ្ជកម្មសហភាពអឺរ៉ុប អាចរកបាននៅ:http://bit.ly/2hnxp64.

# ១០ ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ១ មគ្គុទ្ទេសន៍សម្ភាសសម្រាប់ក្រុមហ៊ុនដែលមិនបានបង់ពន្ធ

**ព័ត៌មានសង្ខេប**

i. ឈ្មោះក្រុមហ៊ុនៈ
ii. ម្ចាស់/អគ្គនាយក/នាយកក្រុមហ៊ុនៈ
iii. ឆ្នាំបង្កើតៈ
iv. ប្រភេទនៃអាជីវកម្ម (សហគ្រាសឯកបុគ្គល/ក្រុមហ៊ុនសហកម្មសិទ្ធ/ក្រុមហ៊ុនសាជីវកម្ម)
v. ដើមទុនៈ
vi. ប្រភេទនៃប្រតិបត្តិការ (ផលិតផល ឬសេវាកម្ម)
vii. ផលរបរប្រចាំឆ្នាំ/ប្រាក់ចំណូល (ប្រហាក់ប្រហែល)

១. តើអ្នកដឹងព័ត៌មានទាក់ទងនឹងប្រព័ន្ធពន្ធដារនៅកម្ពុជាដែរឬទេ?

២. តើអ្នកបានទទួលព័ត៌មានទាក់ទងនឹងប្រព័ន្ធពន្ធដារដែរឬទេ?

៣. តើអ្នកបានដឹងអំពីការធ្វើកំណែទម្រង់ពន្ធដារដែលអគ្គនាយកដ្ឋានពន្ធដារបានធ្វើនាពេលថ្មីៗនេះដែរឬទេ?

៤. តើអ្នកបានកត់សម្គាល់ឃើញថាមានការកែប្រែក្នុងប្រព័ន្ធពន្ធដារនៅកម្ពុជាដែរឬទេ?

៥. ជាទូទៅ តើអ្វីដែលជាការយល់ឃើញរបស់អ្នក ចំពោះប្រព័ន្ធពន្ធដារនៅកម្ពុជា?

៦. តើមានមន្ត្រីពន្ធដារមកបញ្ចុះបញ្ចូល/បង្ខំអ្នកឲ្យចុះបញ្ជីពន្ធដារនៅរដ្ឋបាលសារពើពន្ធដែរឬទេ?

៧. តើពួកគេបញ្ចុះបញ្ចូល/បង្ខំអ្នកយ៉ាងដូចម្តេច?

៨. តើអ្នកពេញចិត្តចំពោះការណែនាំ និងការពន្យល់របស់មន្ត្រីពន្ធដារដែរឬទេ?

៩. ហេតុអ្វីបានជាអ្នកសម្រេចចិត្តមិនចុះបញ្ជីអាជីវកម្មរបស់អ្នកជាមួយនឹងរដ្ឋបាលសារពើពន្ធ?

១០. ប្រសិនបើអ្នកមិនបានចុះបញ្ជីអាជីវកម្មរបស់អ្នកជាមួយនឹងរដ្ឋបាលសារពើពន្ធទេ តើអ្នកត្រូវបានគេដាក់សម្ពាធឲ្យបង់កម្រៃក្រៅផ្លូវការដែរឬទេ?

១១. ប្រសិនបើអ្នករងសម្ពាធឲ្យបង់កម្រៃក្រៅផ្លូវការសម្រាប់ការធ្វើឲ្យអ្នកបានរួចផុតពីកាតព្វកិច្ចបង់ពន្ធជាមួយនឹងរដ្ឋបាលសារពើពន្ធ តើអ្នកយល់ព្រមបង់កម្រៃក្រៅផ្លូវការដែរឬទេ? ចំនួនប៉ុន្មាន?

១២. តើអ្នកមានការពេញចិត្ត ឬមិនពេញចិត្តជាមួយនឹងកម្រៃក្រៅផ្លូវការ/ការសូកប៉ាន់កម្រិតណាដែរ?

១៣. តើមានផលប៉ះពាល់នៃបញ្ហាអំពើពុករលួយមកលើអាជីវកម្មរបស់អ្នកដែរឬទេ?

១៤. តើអ្នកមានសំណូមពរ/អនុសាសន៍ទៅដល់រដ្ឋាភិបាលដើម្បីកែប្រែ និងកែទម្រង់បន្ថែមទៀតដែរឬទេ?

១៥. ជាទូទៅ តើអ្នកមានអនុសាសន៍ដើម្បីធ្វើឲ្យបរិយាកាសពន្ធដារនៅកម្ពុជាប្រសើរឡើងដែរឬទេ?

## ឧបសម្ព័ន្ធ២ មគ្គុទ្ទេសន៍សម្ភាសសម្រាប់ក្រុមហ៊ុនបានបង់ពន្ធ

**ព័ត៌មានសង្ខេប**

i. ឈ្មោះក្រុមហ៊ុនៈ
ii. ម្ចាស់/អគ្គនាយក/នាយកក្រុមហ៊ុនៈ
iii. ឆ្នាំបង្កើតៈ
iv. ប្រភេទនៃអាជីវកម្ម (សហគ្រាសឯកបុគ្គល/ក្រុមហ៊ុនសហកម្មសិទ្ធ/ក្រុមហ៊ុនសាជីវកម្ម)
v. ដើមទុនៈ
vi. ប្រភេទនៃប្រតិបត្តិការ (ផលិតផល ឬសេវាកម្ម)
vii. ប្រភេទអ្នកជាប់ពន្ធៈ
viii. ផលរបរប្រចាំឆ្នាំ/ប្រាក់ចំណូល (ប្រហាក់ប្រហែល)

១. ហេតុអ្វីបានជាអ្នកសម្រេចចិត្តចុះបញ្ជីអាជីវកម្មរបស់អ្នកជាមួយនឹងនាយកដ្ឋានពន្ធដារ (ដោយឆន្ទៈ ឬដោយបង្ខំ)?

២. តើអ្នកចុះបញ្ជីជាមួយនឹងនាយកដ្ឋានពន្ធដារតាមរបៀបណា (តាមរយៈភ្នាក់ងារ ឬដោយខ្លួនឯង)?

៣. តើឯកសារអ្វីខ្លះដែលអ្នកត្រូវបញ្ជូនទៅដើម្បីស្នើសុំចុះបញ្ជី (ប្រសិនជានៅចាំ)?

៤. តើដំណើរការចុះបញ្ជីប្រើប្រាស់អស់រយៈពេលប៉ុន្មាន (ប្រសិនជានៅចាំ)?

៥. តើអ្នកបានបង់ប្រាក់ចំនួនប៉ុន្មាន?

ក. សម្រាប់ថ្លៃចុះបញ្ជី?

ខ. សម្រាប់ថ្លៃពន្ធប៉ាតង់?

៦. តើអ្នកមានទស្សនៈយ៉ាងណាចំពោះប្រព័ន្ធពន្ធដារនៅកម្ពុជា ជាទូទៅ?

៧. ផ្អែកលើការធ្វើកំណែទម្រង់ដ៏ស៊ីជម្រៅលើគោលនយោបាយពន្ធដារ នីតិវិធីសារពើពន្ធ និងរដ្ឋបាលសារពើពន្ធ ដែលបានធ្វើដោយអគ្គនាយកដ្ឋានពន្ធដារនាពេលថ្មីៗនេះ តើអ្នកបានកត់សម្គាល់ឃើញថាមានការកែប្រែដែរឬទេ?

៨. តើអ្នកធ្លាប់មានបទពិសោធន៍បង់ប្រាក់កម្រៃក្រៅផ្លូវការទៅឲ្យមន្ត្រីពន្ធដារ (ពេលស្នើសុំចុះបញ្ជី ពេលប្រកាសពន្ធប្រចាំខែ ពេលស្នើសុំបន្តប៉ាតង់ និងពេលបិទបញ្ជីគណនេយ្យប្រចាំឆ្នាំ) ដែរឬទេ?

៩. តើអ្នករងសម្ពាធឲ្យបង់កម្រៃក្រៅផ្លូវការយ៉ាងដូចម្តេច?

១០. តើអ្នកមានការពេញចិត្ត ឬមិនពេញចិត្តជាមួយនឹងកម្រៃក្រៅផ្លូវការ/ការសូកប៉ាន់កម្រិតណា?

១១. តើមានផលប៉ះពាល់នៃបញ្ហាអំពើពុករលួយមកលើអាជីវកម្មរបស់អ្នកដែរឬទេ?

១២. តើអ្នកមានគំនិត/ដំណោះស្រាយ ដើម្បីទប់ស្កាត់បញ្ហាពុករលួយក្នុងប្រព័ន្ធពន្ធដារដែរឬទេ? ដូចជា

ក. ដំណើរការចុះបញ្ជី

ខ. ការប្រកាសពន្ធប្រចាំខែ

គ. ការបន្តពន្ធប៉ាតង់

ឃ. ការបិទបញ្ជីគណនេយ្យប្រចាំឆ្នាំ និង

ង. ផ្សេងៗ

១៣. តើអ្នកមានសំណូមពរ/អនុសាសន៍ទៅដល់រដ្ឋាភិបាលដើម្បីកែប្រែ និងកែទម្រង់បន្ថែមទៀតដែរឬទេ?

១៤. ជាទូទៅ តើអ្នកមានអនុសាសន៍ដើម្បីធ្វើឲ្យបរិយាកាសពន្ធដារនៅកម្ពុជាប្រសើរឡើងដែរឬទេ?